.ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

អគ្គនាយកដ្ឋានអប់រំ

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

# របាយការណ៍លទ្ធផល

## ស្តីពី

## ការរៀបចំប្រារព្ធទិវាជាតិអំណានលើកទី ៨ ១១ មីនា ២០២៣

## ប្រធានបទ " អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ "



វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

១១ មីនា ២០២៣

# មាតិកា

**ខ្លឹមសារ** **ទំព័រ**


*មាតិកា* ........................................ ១

*សេចក្តីផ្តើម* ........................................ ៣

*I.គោលបំណង* ........................................ ៤

*II.យុទ្ធវិធី* ........................................ ៤

*III.សកម្មភាព និងលទ្ធផលនៃការរៀបចំទិវាជាតិអំណានលើកទី៨* ........................................ ៥

**១.ដំណើរការរៀបចំការប្រារព្ធពិធីទិវាជាតិអំណានលើកទី៨** ........................................ ៥

ក. កិច្ចប្រជុំពិភាក្សា ត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៨ ........................................ ៥

ខ. ការរៀបចំលិខិតស្នាមគតិយុត្តិផ្សេងៗ ........................................ ៦

គ. ការរៀបចំគណៈកម្មការផ្សេងៗសម្រាប់គ្រប់គ្រង និងដឹកនាំទិវាជាតិអំណាន ........................................ ៦

ឃ.ការរៀបចំសន្និសីទសារព័ត៌មាន..... ........................................ ៧

**២.ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី** ........................................ ៩

ក. ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់រាជធានី ខេត្ត ........................................ ៩

ខ. ការជួបប្រជុំរបស់គណៈកម្មការវាយតម្លៃដាក់ពិន្ទុជាមួយបេក្ខជនជ័យលាភី ........................................ ១០

គ. កម្មវិធីបើកការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ ........................................ ១២

ឃ.ការប្រកាសលទ្ធផលប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ ........................................ ១៦

**៣.សកម្មភាពស្តង់តាំងពិព័រណ៍សៀវភៅអបអរសាទរទិវាជាតិអំណានលើកទី៨** ........................................ ១៩

ក. ការសម្ពោធស្តង់តាំងពិព័រណ៍សៀវភៅ ........................................ ១៩

ខ. សកម្មភាព និងលទ្ធផលស្តង់តាំងពិព័រណ៍សៀវភៅ ........................................ ២០

**៤.សិក្ខាសាលា ស្តីពី " ការអភិវឌ្ឍបណ្ណាល័យសាលារៀន "** ........................................ ២០

ក. សុន្ទរកថាបើកសិក្ខាសាលា ........................................ ២០

ខ. បទបង្ហាញរបស់អង្គការ Room to Read ........................................ ២១

គ. បទបង្ហាញ ស្តីពី " ការរៀបចំទិវាជាតិអំណាន " ........................................ ២២

**៥.ការប្រារព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣** ........................................ ២២

**៥.១ កម្មវិធីពេលព្រឹក** ........................................ ២២

ក. របាយការណ៍វឌ្ឍនភាព ស្តីពី " ការរៀបចំទិវាជាតិអំណាន ........................................ ២៣

ខ. សុន្ទរកថាបើកការប្រារព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ ........................................ ២៥

គ. ការប្រគល់ពានរង្វាន់ជ័យលាភី ........................................ ២៧

ឃ.ការអានអត្ថបទរបស់បេក្ខជនជ័យលាភី១ ផ្នែកអានអត្ថបទ ........................................ ២៩

ង. ការស្មូតកំណាព្យរបស់បេក្ខជនជ័យលាភី១ ផ្នែកស្មូតកំណាព្យ ........ ២៩
ច. បាឋកថាស្រាវជ្រាវ ស្ដីពី " វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងបរិបទនៃការអប់រំ......" ២៩
**៥.២ កម្មវិធីពេលរសៀល** ........ ៣០
ក. ការទស្សនាខ្សែវីដេអូ ស្ដីពី " បណ្ណាល័យយើង ដើម្បីកូនចៅយើង " ........ ៣០
ខ. ការស្មូតកំណាព្យដោយជ័យលាភីលេខ២ ផ្នែកស្មូតកំណាព្យ ........ ៣១
គ. វេទិកាពិភាក្សា ស្ដីពី " សារៈសំខាន់របស់អំណានក្នុងការសិក្សា " ........ ៣១
ឃ.ការជូនប័ណ្ណសរសើរ និងរង្វាន់លើកទឹកចិត្តដល់បេក្ខជនមិនទទួលបានជ័យលាភីថ្នាក់ជាតិ... ៣៩
***IV.សេចក្ដីសន្និដ្ឋាន*** ........ ៤០
***V.ឧបសម្ព័ន្ធ*** ........ ៤១
**ឧបសម្ព័ន្ធទី ១** តារាងបញ្ជីឈ្មោះក្រុមហ៊ុន គ្រឹះស្ថានបោះពុម្ព និងស្ដង់ទទួលបន្ទុក ........ ៤១
**ឧបសម្ព័ន្ធទី ២** បញ្ជីឈ្មោះបេក្ខជនចូលរួមការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ.... ៤៤
រូបភាពទី១ បញ្ជីឈ្មោះបេក្ខជនប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី អានអត្ថបទ ...... ៤៤
រូបភាពទី២ បញ្ជីឈ្មោះបេក្ខជនប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី ស្មូតកំណាព្យ.... ៤៦
រូបភាពទី៣ បញ្ជីឈ្មោះបេក្ខជនប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី តែងនិពន្ធ ........ ៤៨
រូបភាពទី៤ បញ្ជីឈ្មោះបេក្ខជនប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី បកស្រាយ ........ ៥០
**ឧបសម្ព័ន្ធទី ៣** បញ្ជីឈ្មោះបេក្ខជនជ័យលាភីថ្នាក់ជាតិ ........ ៥២
រូបភាពទី៥ បញ្ជីឈ្មោះបេក្ខជនជ័យលាភី ផ្នែកអានអត្ថបទ ........ ៥២
រូបភាពទី៦ បញ្ជីឈ្មោះបេក្ខជនជ័យលាភី ផ្នែកស្មូតកំណាព្យ ........ ៥៣
រូបភាពទី៧ បញ្ជីឈ្មោះបេក្ខជនជ័យលាភី ផ្នែកតែងនិពន្ធ ........ ៥៤
រូបភាពទី៨ បញ្ជីឈ្មោះបេក្ខជនជ័យលាភី ផ្នែកបកស្រាយប្រធានបទ ........ ៥៥



## សេចក្តីផ្តើម

យោងអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី " **ទិវាជាតិអំណាន** " ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់សហការជាមួយក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងស្ថាប័នឯកជន ចាប់ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ រៀបចំប្រារព្ធទិវាជាតិអំណានបាន ៧ លើករួចមកហើយចាប់ពី ២០១៦មក។ ក្នុងការរៀបចំទិវាជាតិអំណានកន្លងមក ក្រសួងបានរៀបចំឱ្យមានកម្មវិធីជាច្រើនដូចជា ការតាំងស្តង់ពិព័រណ៍សៀវភៅដែលបង្ហាញពីសមិទ្ធិផលក្នុងស្ថាប័នវិស័យអប់រំ ស្នាដៃនិពន្ធរបស់វីរជនជាតិនិងអ្នកនិពន្ធល្បីៗ ការនិទានរឿង ការប្រឡងប្រណាំងតែងនិពន្ធ ស្មូតកំណាព្យ និងអានអត្ថបទ សម្រាប់ទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " និងការប្រឡងជ្រើសរើសបេក្ខជន ជ័យលាភីដែលមានសមត្ថភាពខ្ពស់ក្នុងការបកស្រាយប្រធានបទអក្សរសិល្ប៍ និងពិសេសមានវាគ្មិនល្បីៗមកធ្វើបាឋកថាទៀតផង ដោយមានការចូលរួម និងគាំទ្រពីមន្ត្រីរាជការ សិស្ស និស្សិត និងមហាជន ដែលមានបរិមាណកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ក្នុងឆ្នាំ២០២១ ជាទិវាជាតិអំណានលើកទី៦ កន្លងមកទោះស្ថិតក្នុងស្ថានភាពរីករាលដាលនៃជំងឺកូវីដ-១៩ និងព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ និងនៅឆ្នាំ២០២២ ជាលើកទី៧ដែលពេលនោះស្ថានភាពនៃជំងឺកូវីដ-១៩ ក៏កំពុងរីករាលដាលនៃប្រភេទថ្មី(អូមីក្រុង)ក៏ក្រសួងអប់រំ យុវជន និងកីឡានៅតែសហការរៀបចំទិវាជាតិអំណានតាមអនឡាញ និងផ្សាយតាមគេហទំព័រ Facebook ផ្លូវការរបស់ក្រសួង បន្តផ្ទាល់ពីកន្លែងប្រារព្ធពិធីពី ទីស្តីការក្រសួង និងពីវិទ្យាស្ថានជាតិអប់រំ តាមកម្មវិធីដូចរៀងរាល់ឆ្នាំផងដែរ។

ឆ្នាំ២០២៣នេះ ជាលក្ខណៈសកល និងដោយឡែកនៅព្រះរាជាណាចក្រកម្ពុជា ស្ថានភាពនៃជំងឺកូវីដ-១៩ មិនទាន់ស្ងប់ស្ងាត់នៅឡើយ ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំឱ្យគ្រប់ការរៀបចំធ្វើសកម្មភាពត្រូវតែផ្តោតការយកចិត្តទុកដាក់អនុវត្តស្តង់ដាប្រតិបត្តិសុខភាព និងសុវត្ថិភាពរបស់ក្រសួងសុខាភិបាល(SOP) ទាំងដំណើរការសាលារៀនសាធារណៈនិងឯកជន និងទាំងដំណើរការនៃកម្មវិធីផ្សេងៗ។ ដោយឡែកឆ្នាំនេះ ក្រសួងនៅតែបានសហការរៀបចំទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ ក្រោមប្រធានបទ " **អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ** " នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ព្រមទាំងផ្សាយបន្តផ្ទាល់តាមទំព័របណ្តាញសង្គម Facebook ផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡាទៀតផង ។

ដើម្បីឱ្យការប្រារព្ធពិធីនៃទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ ប្រព្រឹត្តទៅដោយរលូន និងអធិកអធម ក្រសួងបានរៀបចំឱ្យមានកម្មវិធីសំខាន់ៗ ដូចជា ៖

ក. កម្មវិធីប្រឡងប្រណាំងអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ជ្រើសរើសយកចំណាត់ថ្នាក់ជ័យលាភីពីលេខ១ ដល់លេខ៣ សម្រាប់ទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** "

ខ. ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីចំនួន៣រូប សម្រាប់បកស្រាយប្រធានបទ " *គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល* "

គ. បាឋកថាស្រាវជ្រាវ ស្តីពី "*វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងបរិបទនៃការអប់រំក្នុងសតវត្សទី២១*" ដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

ឃ. កិច្ចពិភាក្សាអំពី " *សារៈសំខាន់របស់អំណានក្នុងការសិក្សា* "

ង. កម្មវិធីតាំងពិព័រណ៍សៀវភៅអបអរសាទរទិវាជាតិអំណានលើកទី៨

ច. សិក្ខាសាលា ស្តីពី " **ការអភិវឌ្ឍបណ្ណាល័យសាលារៀន** " ។

## I. គោលបំណង

ការប្រារព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ ស្ថិតក្រោមប្រធានបទ " *អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ* " មានគោលបំណង ៖

- រំលឹកដល់វីរៈភាព និងគុណូបការៈដ៏ថ្លៃថ្លារបស់ **សម្ដេចព្រះសង្ឃរាជ ជួន ណាត** ដែលលោកបានខិតខំប្រឹងប្រែងតស៊ូពុះពារការពារមរតកវប្បធម៌ជាតិ និងអក្សរសាស្ត្រជាតិ
- បណ្ដុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ ដល់សិស្ស និស្សិត មន្ត្រីរាជការ និងប្រជាជនគ្រប់រូប
- រំលេចឱ្យឃើញពីសមិទ្ធិផលនៃអំណានលើការប្រែប្រួលក្នុងវិស័យអប់រំ។

### ពាក្យស្លោកសម្រាប់ទិវាជាតិអំណាន លើកទី៨

១. អំណានជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត
២. ការបណ្ដុះបញ្ញា គុណវុឌ្ឍិ និងគុណធម៌
៣. ការអានផ្សារភ្ជាប់ជំនាន់មនុស្ស និងនវានុវត្តន៍
៤. អំណានជាមាគ៌ា ទៅរកភាពជោគជ័យក្នុងជីវិត
៥. ការអានអភិវឌ្ឍចំណេះដឹង និងវិជ្ជានិពន្ធ
៦. អំណានជាភោគទ្រព្យមិនចេះរីងស្ងួត
៧. អំណានជាអាថ៌ សំណេរជាខ្នាត ពហុសិក្សា
៨. អំណានជួយរុករកអាថ៌កំបាំងនៅក្នុងលោក
៩. អំណានដំបូងជាមូលដ្ឋាននៃគុណភាពអប់រំប្រកបដោយចីរភាព
១០. បណ្ដុះអំណានពីតូច ជានាឱកាសធំសម្រាប់អនាគត
១១.អំណាននាំឱ្យអ្នកក្លាហាន និងឈ្លាសវៃ ។

## II. យុទ្ធវិធី

ដើម្បីឱ្យការប្រារព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ បានប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលគាប់ប្រសើរ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំយន្តការសំខាន់ៗតាមដំណាក់កាលដូចខាងក្រោម ៖

**១- ការត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៨**

ក. ការប្រជុំពិភាក្សា ត្រៀមរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣
ខ. ការរៀបចំលិខិតស្នាមគតិយុត្តិផ្សេងៗ សម្រាប់ជំរុញ និងគាំទ្រការប្រារព្ធពិធីទិវាជាតិអំណាន
គ. ការរៀបចំគណៈកម្មការផ្សេងៗសម្រាប់គ្រប់គ្រង និងដឹកនាំ ដំណើរការទិវាជាតិអំណាន
ឃ. ការរៀបចំធ្វើសន្និសីទសារព័ត៌មាន។

**២- ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី**

ក. ការប្រឡងប្រណាំង អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ថ្នាក់រាជធានី ខេត្ត
ខ. ការប្រឡងប្រណាំង អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ថ្នាក់ជាតិ
គ. ការប្រឡងប្រណាំង បកស្រាយប្រធានបទ " *គុណតម្លៃមនុស្ស ក្នុងសម័យឌីជីថល* "

ឃ. សិក្ខាសាលា ស្តីពី " *ការអភិវឌ្ឍបណ្ណាល័យសាលារៀន* "

ង. ដំណើរការស្តង់តាំងពិព័រណ៍សៀវភៅ ដើម្បីអបអរសាទរទិវាជាតិអំណានលើកទី៨

**៣- ការប្រារព្ធទិវាជាតិអំណានលើកទី៨ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣**

## III. សកម្មភាព និងលទ្ធផលនៃការរៀបចំទិវាជាតិអំណានលើកទី៨

### ១.ការត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៨

**ក. កិច្ចប្រជុំពិភាក្សា ត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣**

**ក.១.** កិច្ចប្រជុំថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣ ស្តីពី ការត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៨ ស្ថិតក្នុងបន្ទប់ធ្វើការ និងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ទន់ សារ៉ឹម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ លទ្ធផលអង្គប្រជុំមាន៖

. កំណត់បានជម្រើសទីតាំងប្រារព្ធពិធីទិវាជាតិអំណាន

. ជ្រើសរើសបានប្រធានបទ សម្រាប់ទិវាជាតិអំណានលើកទី៨ មួយចំនួន

. ជ្រើសរើសប្រធានបទសម្រាប់វាគ្មិនចូលរួមបកស្រាយ

. ជ្រើសរើសពាក្យស្លោក សម្រាប់ទិវាជាតិអំណានលើកទី៨ មួយចំនួន

. ការកំណត់និតិវិធី និងការជ្រើសរើសវិញ្ញាសាប្រឡងប្រណាំងអាន ស្មូតកំណាព្យ និងតែងនិពន្ធ

. ការស្នើសុំប្រធានបទសម្រាប់មហាជន។

**ក.២** កិច្ចប្រជុំថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ស្តីពី ការរៀបចំផែនការសកម្មភាពការប្រារព្ធទិវាជាតិអំណាន



លើកទី៨ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។ អង្គប្រជុំស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាសរុប១៥នាក់។ ដោយឡែកក្នុងកម្មវិធីកិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមតាមអនឡាញ ពីថ្នាក់ដឹកនាំក្រសួង អង្គភាពថ្នាក់កណ្តាល និងតំណាងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត សរុប ១១៨ នាក់។ លទ្ធផលនៃកិច្ចប្រជុំនេះមាន ៖

. កំណត់កន្លែងប្រារព្ធពិធីទិវាជាតិអំណានលើកទី៨ នឹងរៀបចំនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

. កំណត់ប្រធានបទគឺ " អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ " និងកំណត់ពាក្យស្លោកចំនួន១១

. ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី ផ្នែកអាន ស្មូតកំណាព្យ និងតែងនិពន្ធ ត្រូវបានផ្តល់នាទីជូន **លោកជំទាវ ទន់ សារ៉ឹម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកដឹកនាំអនុវត្ត

. បាឋកថាស្រាវជ្រាវស្តីពី "*វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ក្នុងបរិបទនៃការអប់រំក្នុងសតវត្សទី២១*" ដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

. កិច្ចពិភាក្សា ស្តីពី " សារៈសំខាន់របស់អំណានក្នុងការសិក្សា " ដោយវាគ្មិនកិត្តិយស

. ការរៀបចំគណៈកម្មការវាយតម្លៃការប្រឡងប្រណាំង និងបកស្រាយប្រធានបទ រួមទាំងកិច្ចការមួយចំនួនទៀត នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាសហការជាមួយអង្គភាពពាក់ព័ន្ធទទួលបន្ទុករៀបចំ

. ការរៀបចំគណៈកម្មការព័ត៌មាននិងផ្សព្វផ្សាយ ដឹកនាំដោយ **លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ។**

**ក.៣** កិច្ចប្រជុំថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ នៅ**បណ្ណាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**



**និងលោកជំទាវ** បឺងត្របែក របស់គណៈកម្មការរៀបចំការតាំងពិព័រណ៍សៀវភៅ ជាមួយនឹងក្រុមហ៊ុន និងគ្រឹះស្ថានបោះពុម្ពសៀវភៅមួយចំនួន ដើម្បីរៀបចំចាប់ឆ្នោតជូនក្រុមហ៊ុន និងគ្រឹះស្ថាន ទទួលយកស្តង់តាំងពិព័រណ៍សៀវភៅសម្រាប់ត្រៀមរៀបចំតាំងពិព័រណ៍សៀវភៅអបអរសាទរទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣។

**ក.៤** កិច្ចប្រជុំថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២ របស់គណៈកម្មការរៀបចំការតាំងពិព័រណ៍សៀវភៅជាមួយនឹង



ក្រុមយុវជនស្ម័គ្រចិត្តបានប្រព្រឹត្តទៅនៅ **បណ្ណាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវ** បឺងត្របែក ដើម្បីបង្ហាញពី រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមយុវជនស្ម័គ្រចិត្ត ធ្វើការចែករំលែកបទពិសោធន៍ និងណែនាំការងារមួយចំនួន សម្រាប់រៀបចំតាំងពិព័រណ៍សៀវភៅក្នុងទិវាជាតិអំណានលើកទី៨ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ នាពេលខាងមុខ។

**ខ. ការរៀបចំលិខិតស្នាមគតិយុត្តិផ្សេងៗ**

ក្រោមកិច្ចសហការរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ជាមួយអង្គភាពពាក់ព័ន្ធ ក្រសួងបានរៀបចំចេញលិខិតជាច្រើនសម្រាប់ជំរុញ និងគាំទ្រដំណើរការអនុវត្ត មានដូចជា ៖

**ខ.១** លិខិតលេខ ០៩ អយក.សជណ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពី ការរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៨ ដែលនឹងប្រព្រឹត្តទៅថ្ងៃសៅរ៍ ទី១១ ខែមីនា ឆ្នាំ២០២៣ ក្រោមប្រធានបទ " ***អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ*** " និងការប្រឡងប្រណាំងជ្រើសរើសជ័យលាភី ៣រូប សម្រាប់បកស្រាយប្រធានបទ "**គុណតម្លៃមនុស្ស ក្នុងយុគសម័យឌីជីថល**" ជូនដំណឹងដល់មន្ត្រីអប់រំ គ្រូបង្រៀន គរុសិស្ស និស្សិត និងសាធារណជនទូទៅអញ្ជើញចូលរួម។

**ខ.២** លិខិតលេខ ៦១៦ អយក.អកស ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពី ការជម្រាបមកលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ឱ្យអនុវត្តសេចក្តីណែនាំលេខ៤៧ អយក.សណន ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី ការប្រារព្ធទិវាជាតិអំណាន ១១ មីនា។

**ខ.៣** លិខិតលេខ ៦១៥ អយក.អកស ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ ជម្រាបជូន ឯកឧត្តមបណ្ឌិតនាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សំណើសុំទីកន្លែងរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ ។

**គ. ការរៀបចំគណៈកម្មការផ្សេងៗសម្រាប់គ្រប់គ្រង និងដឹកនាំទិវាជាតិអំណាន**

**គ.១** លិខិតលេខ ០៦ អយក.សសរ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពី ការបង្កើតគណៈកម្មការគ្រប់គ្រង

និងដឹកនាំការរៀបចំទិវាជាតិអំណាន និងការកំណត់ភារកិច្ចរបស់អនុគណៈកម្មការ។

**គ.២** លិខិតលេខ ៦៧៧ អយក.ឧទន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ដីពី ការចាត់តាំងគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំងអាន ស្នូតកំណាព្យ និងតែងនិពន្ធ និងគណៈកម្មការវាយតម្លៃដាក់ពិន្ទុក្នុងការបកស្រាយប្រធានបទ និងភារកិច្ចរបស់គណៈកម្មការនីមួយៗ។

**គ.៣** លិខិតលេខ ០៨ អយក.សសរ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣ ស្ដីពី ការបង្កើតគណៈកម្មការរៀបចំការតាំងពិព័រណ៍សៀវភៅដើម្បីអបអរសាទរទិវាជាតិអំណានលើកទី៨ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ និងការកំណត់ភារកិច្ចដឹកនាំ គ្រប់គ្រង សម្របសម្រួល និងត្រួតពិនិត្យគ្រប់គ្រងសកម្មភាពនៃការរៀបចំតាំងពិព័រណ៍សៀវភៅ។

**គ.៤** លិខិតលេខ ១០៣៣ អយក.រប ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ គោរពជូន ឯកឧត្តមអនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិ រៀបចំបុណ្យជាតិ-អន្តរជាតិ សំណើសុំកិច្ចសហការក្នុងការរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៨។

**គ.៥** លិខិតលេខ១០៤៩ អយក.អកស ចុះថ្ងៃទី២៨ខែកុម្ភៈ ឆ្នាំ២០២៣ គោរពជូន លោកជំទាវអគ្គនាយិកាស្ថានីយ៍វិទ្យុ និងទូរទស្សន៍ប៉ុស្តិ៍បាយ័ន សំណើចាត់អ្នកសារព័ត៌មានមកចូលរួម និងយកព័ត៌មានក្នុងពិធីប្រារព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

**គ.៦** លិខិតលេខ ១០៥០ អយក.អកស ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ គោរពជូន ឯកឧត្តមអគ្គនាយកស្ថានីយ៍ទូរទស្សន៍ប៉ុស្តិ៍ហង្សមាស សំណើចាត់អ្នកសារព័ត៌មានមកចូលរួម និងយកព័ត៌មានក្នុងពិធីប្រារព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

**គ.៧** លិខិតលេខ ១០៥១ អយក.អកស ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ គោរពជូន ឯកឧត្តមអគ្គនាយកស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា សំណើចាត់អ្នកសារព័ត៌មានមកចូលរួម និងយកព័ត៌មានក្នុងពិធីប្រារព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

**គ.៨** លិខិតលេខ ១០៥២ អយក.អកស ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួង ប្រធានអង្គភាពថ្នាក់កណ្ដាល ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានអង្គការជាតិ និងអន្តរជាតិ ចូលរួមការប្រារព្ធទិវាជាតិអំណានលើកទី៨ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។

**គ.៩** លិខិតលេខ ១០៥៣ អយក.អកស ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ជម្រាបជូនលោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចូលរួម និងចាត់មន្ត្រីជំនាញផ្នែកបណ្ណាល័យចូលរួម សិក្ខាសាលា ស្ដីពី " *ការអភិវឌ្ឍបណ្ណាល័យសាលារៀន* " នឹងប្រព្រឹត្តទៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ នៅសាលប្រជុំA នៃវិទ្យាស្ថានបច្ចេកវិទ្យា ។



**ឃ. ការរៀបចំសន្និសីទសារព័ត៌មាន**

ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១៤:៣០ នៅសាលប្រជុំ " ក " ទីស្ដីការក្រសួងអប់រំ យុវជន និង កីឡា មានរៀបចំសន្និសីទសារព័ត៌មាន ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងមានការអញ្ជើញចូលរួម ពីឯកឧត្តមប្រធានអគ្គនាយកគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ

ថ្នាក់ដឹកនាំនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាអង្គការដៃគូអភិវឌ្ឍ និងក្រុមអ្នកសារព័ត៌មានមួយចំនួន។ ខ្លឹមសារមាន ៖

**១.ប្រសាសន៍របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បានផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម ៖

**ក. បុព្វហេតុ និងគោលបំណង**

. ការប្រារព្ធទិវាជាតិអំណានលើកទី៨ គឺថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ ធ្វើនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

. ថ្ងៃទី១១ ខែមីនា នេះ ជាថ្ងៃខួបកំណើតរបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត** ដោយក្រសួងបានជ្រើសយកថ្ងៃនេះ រៀបចំប្រារព្ធទិវាជាតិអំណាន ដើម្បីរំលឹកដល់វីរៈភាព និងពីគុណូបការៈដ៏ថ្លៃថ្លាដល់សម្តេចព្រះសង្ឃរាជ បានខិតខំប្រឹងប្រែងតស៊ូពុះពារការពារមរតកវប្បធម៌អក្សរសាស្ត្រខ្មែរ ដែលលោកបានចំណាយពេលពេញមួយជីវិតរបស់លោកដើម្បីជួយលើកស្ទួយមិនត្រឹមតែវប្បធម៌ជាតិទេ តែលើកស្ទួយអក្សរសាស្ត្រជាតិផងដែរ ដូចជាការរៀបចំវចនានុក្រម **ជួន ណាត** ជាដើម។

. លើកកម្ពស់ទម្លាប់អាន ជំរុញវប្បធម៌អាន ជាពិសេសក្នុងចំណោមយុវជនកម្ពុជា ក៏ដូចជាលើកកម្ពស់សមត្ថភាពអាន តែងនិពន្ធ និងស្រាវជ្រាវសំដៅរួមចំណែកការពារ និងលើកកម្ពស់វប្បធម៌ជាតិអរិយធម៌ខ្មែរ ព្រមទាំងពង្រឹង និងពង្រីកចំណេះដឹងរបស់ពលរដ្ឋកម្ពុជាគ្រប់រូប។

**ខ.លំនាំសកម្មភាពនៃការរៀបចំទិវាជាតិអំណានលើកទី៨**

. ពីមួយឆ្នាំទៅមួយឆ្នាំ ការរៀបចំទិវាជាតិអំណាន កាន់តែមានលក្ខណៈធំទូលាយឡើងៗ និងកាន់តែមានលក្ខណៈផុសផុលជាទីចាប់អារម្មណ៍របស់មហាជន និងការចូលរួមពីគ្រប់មជ្ឈដ្ឋាន ដោយត្រូវបានរៀបចំឡើងពីថ្នាក់ក្រោមជាតិ ដល់ថ្នាក់ជាតិ និងមានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត រៀបចំឱ្យមានកម្មវិធីសំខាន់ៗជាច្រើន ដើម្បីលើកកម្ពស់ទិវាជាតិអំណាន និងលើកកម្ពស់ការអាននៅកម្ពុជា។

. ទោះបីស្ថិតនៅក្នុងបរិបទកូវីដក៏ដោយ ក៏ក្រសួងបានរៀបចំទិវាជាតិអំណានជាលក្ខណៈអនឡាញផងដែរ

. ដោយឡែកទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ បានស្ថិតក្រោមប្រធានបទ " *អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ* " ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** ដោយក្រសួងបានរៀបចំ ការប្រកួតប្រជែងបកស្រាយប្រធានបទស្តីពី *"គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល"* និងវេទិកាពិភាក្សា ស្តីពី "*សារៈសំខាន់នៃអំណានក្នុងការសិក្សា*"។ ជាមួយគ្នានេះដែរ ក្នុងនាមឯកឧត្តមផ្ទាល់ ក៏នឹងចូលរួមធ្វើបាឋកថាមួយ ស្តីពី " *វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ក្នុងបរិបទនៃការអប់រំក្នុងសតវត្សទី២១* " ។

. ជារៀងរាល់ឆ្នាំ ឯកឧត្តមរដ្ឋមន្ត្រី តែងតែបានរៀបចំជាបាឋកថាពិសេសលើប្រធានបទផ្សេងៗ ពាក់ព័ន្ធជាមួយអក្សរសាស្ត្រក្តី ភាសាខ្មែរក្តី ហើយបាឋកថាទាំងនោះក៏ត្រូវបានបោះពុម្ពផ្សាយជាសៀវភៅផងដែរដែលសហការជាមួយអង្គការស៊ីប៉ាជាអ្នករៀបចំ។

**គ.កម្មវិធីសំខាន់ៗនៃទិវាជាតិអំណានលើកទី៨**

. ថ្ងៃទី៨ ដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ការប្រឡងប្រណាំងថ្នាក់ជាតិលើវិញ្ញាសា អានអត្ថបទ ស្មូត កំណាព្យ និងតែងនិពន្ធ និងការប្រឡងប្រណាំងបកស្រាយប្រធានបទ "*គុណតម្លៃមនុស្សក្នុងយុគសម័យ ឌីជីថល*"

. ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ សិក្ខាសាលា ស្តីពី " *ការអភិវឌ្ឍបណ្ណាល័យសាលាបឋមសិក្សា* "

. ពីថ្ងៃទី១០ ដល់ថ្ងៃទី១២ នឹងមានការដាក់សម្ពោធដាក់តាំងពិព័រណ៍សៀវភៅចំនួន ១១០ស្តង់ មកពី ៨៧

ក្រុមហ៊ុននៅបរិវេណវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាដោយបើកទូលាយជូនសាធារណៈជន ចូលរួមទស្សនា អាន និងជាវសៀវភៅដោយសេរី។

. ថ្ងៃទី១១ មីនា ២០២៣ ជាថ្ងៃប្រារព្ធទិវាជាតិអំណានលើកទី៨ ដែលមានអ្នកចូលរួមប្រមាណ៤០០០នាក់ ក៏និងមានការផ្សព្វផ្សាយជូនសាធារណៈជនតាមហ្វេកប៊ុកផ្លូវការរបស់ក្រសួងថែមទៀត។

. រសៀលថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ មានការចូលរួមពី **ព្រះមុនីកោសល្យបណ្ឌិត យ៉ន សេងយៀត** សាកលវិទ្យាធិការរងនៃពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ និង **លោកសាស្ត្រាចារ្យបណ្ឌិត អាំង ជូលាន** នរវិទូខ្មែរ និងជាម្ចាស់ពានរង្វាន់ ហ្វ៊ូគូអូកា នៃប្រទេសជប៉ុន ដើម្បីចូលរួមបកស្រាយប្រធានបទ ស្តីពី "*សារៈសំខាន់របស់អំណានក្នុងការសិក្សា* " ថាតើការអានមានសារៈសំខាន់អ្វីខ្លះក្នុងការសិក្សា។

**ឯកឧត្តម បណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** បានអំពាវនាវ ដល់សម្តេច ឯកឧត្តម សិស្សានុសិស្ស និងសាធារណជនទាំងអស់ អាចអញ្ជើញចូលរួមដោយផ្ទាល់ ឬចូលរួមតាមហ្វេកប៊ុកក្តី និងតាមដាននូវព្រឹត្តិការណ៍ផ្សេងៗ ពាក់ព័ន្ធជាមួយនឹងការប្រារព្ធទិវាជាតិអំណាននេះដូចជា ការចូលរួមដោយផ្ទាល់ក្នុងកម្មវិធីសិក្ខាសាលាក្តី នៅក្នុងស្តង់ពិព័រណ៍សៀវភៅក្តី ពីថ្ងៃទី១០ ដល់ថ្ងៃទី១២ នៅបរិវេណវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ ជាពិសេសការនាំកូនចៅ មកចូលរួមនៅក្នុងការតាំងពិព័រណ៍សៀវភៅ គឺជាការបណ្តុះកូនពីតូចឱ្យចូលរួមពិព័រណ៍ ចូលរួមបណ្ណាល័យនៅតូចក្តី នៅធំទង់ក្តី នឹងធ្វើឱ្យកូនមានការចាប់អារម្មណ៍ និងលើកទឹកចិត្តដល់ការអានផងដែរ។

**២.កម្មវិធីសំណួរពីអ្នកសារព័ត៌មាន**

មានអ្នកសារព័ត៌មាន៤រូប មកពីអង្គភាពសារព័ត៌មានផ្សេងៗគ្នា បានសួរសំណួរ បានផ្តោតលើខ្លឹមសារអំណាន៖. ការជួយអនក្ខរជនពាក់ព័ន្ធនឹងអក្ខរកម្មគឺក្រសួងមាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ជាអ្នកទទួលបន្ទុកដើម្បីជួយអប់រំអនក្ខរជន។

. ពាក់ព័ន្ធការអានក្រសួងអប់រំ យុវជន និងកីឡា បានពង្រឹងការអានពីថ្នាក់ដំបូងចាប់ពីថ្នាក់ទី១,២ និង៣

. ទាក់ទងនឹងការជួយសិស្សដើម្បីការអាន គឺក្នុងកម្មវិធីសិក្សាភាសាខ្មែរ យើងមានការសរសេរតាមអាន និងតែងសេចក្តី ពិសេសឱ្យសិស្សអាន តម្រូវឱ្យសិស្សអាន។

. ទាក់ទងនឹងការជ្រើសរើសសៀវភៅអាន គឺរើសតាមកម្រិតវ័យ និងតាមចំណង់ចំណូលចិត្ត

. ការចូលរួមចំណែករបស់ឪពុកម្តាយក្នុងការអានរបស់កូន គឺជាកត្តាសំខាន់សម្រាប់កូនក្នុងការអាន។

## ២.ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី

### ក. ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់រាជធានី ខេត្ត



បន្ទាប់ពីបានទទួលលិខិតលេខ ៦១៦ អយក.អកស ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការអនុវត្តសេចក្តីណែនាំលេខ ៤៧ អយក.សណន ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការប្រារព្ធទិវាជាតិអំណាន ១១មីនា រួចមក មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តបានរៀបចំការប្រឡងប្រណាំងអានអត្ថបទ ស្មូតកំណាព្យ និង តែងនិពន្ធ ដើម្បីជ្រើសរើសបេក្ខជនជ័យលាភីមានចំណាត់ថ្នាក់ពីលេខ១ដល់លេខ៣ សម្រាប់ការចូលរួមប្រឡងប្រណាំងថ្នាក់ជាតិ។

## ខ. ការជួបប្រជុំរបស់គណៈកម្មការវាយតម្លៃដាក់ពិន្ទុជាមួយនឹងបេក្ខជនជ័យលាភី

ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង១៥:០០ នាទី នៅសាលប្រជុំជាន់ទី១ នៃអគាររដ្ឋបាលថ្មីក្រសួង



អប់រំ យុវជន និងកីឡា មានរៀបចំកម្មវិធីជួបសំណេះសំណាលរបស់គណៈកម្មការវាយតម្លៃដាក់ពិន្ទុ ជាមួយនឹងបេក្ខជន ក្នុងបំណងបង្ហាញពីលក្ខណៈបច្ចេកទេសមួយចំនួន ដើម្បីឱ្យការប្រឡងប្រណាំងនៃវិញ្ញាសានីមួយៗបានប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលល្អ ពិសេសជ័យលាភីថ្នាក់ជាតិរបស់បេក្ខជនម្នាក់ៗទាំង៣វិញ្ញាសា។ កម្មវិធីនេះស្ថិតក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី គណៈកម្មការវាតម្លៃដាក់ពិន្ទុការ បេក្ខជនទាំង៣វិញ្ញាសា ប្រតិភូដឹកនាំបេក្ខជន អ្នកអាណាព្យាបាលសិស្សសរុបប្រមាណ ២០០ នាក់។

### ខ.១ ប្រសាសន៍របស់ **ឯកឧត្តម ជ័យ ចាប ទីប្រឹក្សារាជរដ្ឋាភិបាល និងជាប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំង តែងនិពន្ធ**



មានខ្លឹមសារសំខាន់ៗដូចខាងក្រោម ៖

. ការតែងនិពន្ធបានល្អ ផ្អែកលើចំណេះដឹងទូលំទូលាយទោះបីជាកំណាព្យ ឬការនិពន្ធអ្វីផ្សេងៗ

. ការសរសេរកំណាព្យបានល្អ អាស្រ័យលើការសរសេរច្រើនដង ប្រកបដោយភាពអត់ធ្មត់ និងខន្តី ដោយចេះក្បួន ទាំងពាក្យរាយ និងពាក្យកាព្យ

. លក្ខណៈពិសេសនៃការតែងនិពន្ធគឺ ខ្លីតែមានខ្លឹមសារដោយប្រមូលគំនិតធំៗឱ្យនៅខ្លីបំផុត ដោយមានអត្ថន័យទូលាយ និងនៅពេលសរសេរនិពន្ធគួរមានក្រដាស២សន្លឹក ដោយ១សន្លឹកសរសេរជាព្រាងគំនិតដែលបានលេចចេញមកថ្មីៗ និង១ទៀតសរសេរនិពន្ធ។

. ការសរសេរកំណាព្យ ត្រូវគិតលើ ១)កំណាព្យពាក្យជួន គឺវាយធម្មតា កំណាព្យកម្រងកែវ និងបរិយាស័ព្ទ ២)អត្ថរូប គឺសំខាន់ស្វែងយល់អត្ថន័យ ព្រោះអត្ថន័យជាគ្រឿងលម្អ។

ដូចនេះការតែងនិពន្ធត្រូវគិតលើ របៀបតែងនិពន្ធ របៀបសរសេរ និងរបៀបបង្ហាញ។

### ខ.២ ប្រសាសន៍របស់ **លោក ឃឹម សារិន អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងជាប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំងអានអត្ថបទ**



បានបង្ហាញពីលក្ខណៈវិនិច្ឆ័យដាក់ពិន្ទុផ្នែកអានអត្ថបទ សរុប ១០ ពិន្ទុ មានដូចជា ៖

. អានអត្ថបទបានលឿន គោរពឃ្លា ល្បះបានត្រឹមត្រូវ ២ ពិន្ទុ

. សំឡេងច្បាស់ ត្រឹមត្រូវតាមសូរពាក្យ សំនៀងច្បាស់ ៣ ពិន្ទុ

. មិនខុសពាក្យ មិនរំលងពាក្យ ៤ ពិន្ទុ

. ឥរិយាបថសមរម្យ ១ ពិន្ទុ

ខ.៣ ប្រសាសន៍របស់ **លោកជំទាវ បណ្ឌិត សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង
**កីឡា និងជាប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំង ស្មូតកំណាព្យ**




មានខ្លឹមសារសំខាន់ៗដូចខាងក្រោម ៖

. ការស្មូតកំណាព្យ ត្រូវចូលអារម្មណ៍ ចូលតួ ដើម្បីអ្នកស្តាប់ និងអ្នកមើល បានចាប់អារម្មណ៍ និងជក់ចិត្ត

. ល័ក្ខខ័ណ្ឌ និងក្របខណ្ឌ នៃការវាយតម្លៃដាក់ពិន្ទុ សរុបមាន ១០ពិន្ទុដោយវាយតម្លៃលើ៖

ក.ស្មូតតាមលំនាំបទបានច្បាស់លាស់ដោយយកតាមលំនាំបទរបស់ឯកឧត្តម **យ៉ាន់ មួរិន** ដោយមានការទទួលស្គាល់ ពីរាជបណ្ឌិត្យសភាកម្ពុជា និង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ខ. មានសំឡេងពិរោះក្រអៅក្រអួន

គ. សំឡេងមិនភ្លាត់ មិនភ្លាត់ដាច់

ឃ. មានទឹកមុខ កាយវិកា ទៅតាមបទ និងខ្លឹមសារបទ

លោកជំទាវបណ្ឌិត បានបញ្ជាក់ ជានាដូនយុត្តិធម៌ សមធម៌ និងតម្លាភាព ជូនដល់បេក្ខជន ។

ខ.៤ ការប្រកាសពីប្រាក់រង្វាន់ និងរង្វាន់លើកទឹកចិត្តសម្រាប់បេក្ខជនជ័យលាភី

លោក **ម៉ុក វ៉ាស៊ី** ប្រធានបណ្ណាល័យ សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវ និងជាលេខាធិការនៃគណៈកម្មការគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណានបានប្រកាសជូនអង្គពិធីពី ពានរង្វាន់ និងប្រាក់រង្វាន់ សម្រាប់ផ្តល់ជូនបេក្ខជនជ័យលាភី និងលើកទឹកចិត្តដល់បេក្ខជនមិនទទួលបានជ័យលាភី មាន៖

**ក.ផ្នែកអានអត្ថបទ៖** ជ័យលាភី **លេខ១** . រង្វាន់លើកទឹកចិត្តចំនួន ៣.០០០.០០០ រៀល
. " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ១
. ប្រកាសនីយបត្រ ១ និង កាបូប១ និង Kindle White Paper ១

ជ័យលាភី **លេខ២** . រង្វាន់លើកទឹកចិត្តចំនួន ២.០០០.០០០ រៀល
. " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ១
. ប្រកាសនីយបត្រ ១ និងកាបូប១ និង Kindle White Paper ១

ជ័យលាភី **លេខ៣** . រង្វាន់លើកទឹកចិត្តចំនួន ១.០០០.០០០ រៀល
. " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ១
. ប្រកាសនីយបត្រ ១ និងកាបូប១ និង Kindle White Paper ១

**ខ.ផ្នែកស្មូតកំណាព្យ៖** ជ័យលាភី **លេខ១** . រង្វាន់លើកទឹកចិត្តចំនួន ៤.០០០.០០០ រៀល
. " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ១
. ប្រកាសនីយបត្រ ១ និងកាបូប១ និង Kindle White Paper ១

ជ័យលាភី **លេខ២** . រង្វាន់លើកទឹកចិត្តចំនួន ៣.០០០.០០០ រៀល
. " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ១
. ប្រកាសនីយបត្រ ១ និងកាបូប១ និង Kindle White Paper ១

ជ័យលាភី **លេខ៣** . រង្វាន់លើកទឹកចិត្តចំនួន ២.០០០.០០០ រៀល

. " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រ ១ និងកាបូប១ និង Kindle White Paper ១

**គ.ផ្នែកតែងនិពន្ធ៖** ជ័យលាភី **លេខ១** . រង្វាន់លើកទឹកចិត្តចំនួន ៦.០០០.០០០ រៀល

. " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រ ១ និងកាបូប១ និង Kindle White Paper ១

ជ័យលាភី **លេខ២** . រង្វាន់លើកទឹកចិត្តចំនួន ៥.០០០.០០០ រៀល

. " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រ ១ និងកាបូប១ និង Kindle White Paper ១

ជ័យលាភី **លេខ១** . រង្វាន់លើកទឹកចិត្តចំនួន ៤.០០០.០០០ រៀល

. " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " ១

. ប្រកាសនីយបត្រ ១ និងកាបូប១ និង Kindle White Paper ១

**ឃ.ចំពោះបេក្ខជនមិនបានទទួលជ័យលាភី**

ចំពោះបេក្ខជនប្រឡងប្រណាំងទាំង៣ផ្នែកដែលមិនបានទទួលជ័យលាភី សរុបមាន៦៦នាក់ ក៏នឹងត្រូវបានទទួលលិខិតថ្លែងអំណរគុណ ១ និងកាបូប១ ផងដែរ។

ប្រសាសន៍របស់ **លោកជំទាវ ទន់ សារអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** បានបញ្ជាក់



ថា ការប្រឡងប្រណាំង អាន ស្មូតកំណាព្យ និងតែងនិពន្ធឆ្នាំនេះបាននាំមកនូវភាពសប្បាយរីករាយនិងភាពកក់ក្តៅ ដោយបេក្ខជនទាំងអស់បានមកជួបផ្ទាល់ ជាមួយគណៈកម្មការវាយតម្លៃដាក់ពិន្ទុ និងបានជួបឳពុកម្តាយដែលមកជួយលើកទឹកចិត្តក្នុងការប្រឡង តែក៏សូមយើងត្រូវតែបន្តអនុវត្តនូវវិធានការ៣កុំ និង៣ការពារ ដោយយកចិត្តទុកដាក់។

**គ. កម្មវិធីបើកការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ**



ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ៧:៣០នាទី នៅសាលប្រជុំជាន់ទី១ អគាររដ្ឋបាលថ្មីក្រសួងអប់រំ យុវជននិងកីឡា មានកិច្ចប្រជុំបើកការប្រឡងប្រណាំង អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ដើម្បីជ្រើសរើសជ័យលាភីថ្នាក់ជាតិ។ កិច្ចប្រជុំ ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** និងមានការអញ្ជើញចូលពីគណៈកម្មការវាយតម្លៃដាក់ពិន្ទុ បេក្ខជន ប្រតិភូដឹកនាំតាមរាជធានី ខេត្ត និងអ្នកអាណាព្យាបាលបេក្ខជន សរុបប្រមាណ ២០០នាក់ ។

**គ.១** របាយការណ៍វឌ្ឍនភាពនៃការប្រឡងប្រណាំង អាន ស្មូតកំណាព្យ និងតែងនិពន្ធ

លោក **ស៊ុន ប៊ុណ្ណា** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា បានធ្វើរបាយការណ៍ជូនគណៈអធិបតី និង

អង្គពិធីថា បន្ទាប់ពីក្រសួងទទួលបានអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី "**ទិវាជាតិអំណាន** " ក្រសួងរៀបចំទិវាជាតិអំណានបាន៧លើកមកហើយ ក្នុងនោះមាន៖



. ឆ្នាំ២០១៦ ការរៀបចំទិវាជាតិអំណាន ត្រូវបានរៀបចំឱ្យមាន ការអានអត្ថបទ ការសូត្រកំណាព្យដែលត្រូវរៀបចំធ្វើធ្វើឡើងជានិមិត្តរូប។

. ចាប់ពីឆ្នាំ ២០១៧ មក ការរៀបចំទិវាជាតិអំណាន ក្រសួងបានរៀបចំឱ្យមានកម្មវិធីប្រឡងប្រណាំង អានអត្ថបទ សូត្រកំណាព្យ និងតែងនិពន្ធ ថ្នាក់រាជធានី ខេត្ត និងបាននាំយកបេក្ខជនជ័យលាភី មកចូលរួមប្រឡងប្រណាំងជ្រើសរើសជ័យលាភីថ្នាក់ជាតិដើម្បីទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន**" និងមានការធ្វើបាឋកថារបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ព្រមទាំងការប្រឡងជ្រើសរើសបេក្ខជន ជ័យលាភីសម្រាប់បកស្រាយស្នាដៃអក្សរសិល្ប៍។

. ក្នុងដំណាក់កាលកូវីដ-១៩ ក្រសួងក៏នៅបានរៀបចំទិវាជាតិអំណាន និងរក្សាដំណើរការកម្មវិធីទិវាជាតិអំណានដូចបណ្តារាល់ឆ្នាំដែរ តែត្រូវបានប្រព្រឹត្តទៅតាមអនឡាញ និងពាក់កណ្តាលអនឡាញ។

. ដោយឡែកឆ្នាំ២០២៣ នេះ ការរៀបចំទិវាជាតិអំណានលើកទី៨ ត្រូវបានស្ថិតក្រោមប្រធានបទ "*អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ* " និងត្រូវបានរៀបចំឱ្យមានកម្មវិធីប្រឡងប្រណាំង អានអត្ថបទ ការសូត្រកំណាព្យ និងតែងនិពន្ធ ដើម្បីទទួល " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** " និងការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីបកស្រាយប្រធានបទ ។

គ.២ ប្រសាសន៍បើកកម្មវិធីប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ




ថ្លែងក្នុងពិធីបើកការប្រឡងប្រណាំង អានអត្ថបទ សូត្រកំណាព្យ និងតែងនិពន្ធ **ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** មានប្រសាសន៍ដូចខាងក្រោម៖

. ការកោតសរសើរ និងអរគុណ ដល់គណៈកម្មការរៀបចំទិវាជាតិអំណានលើកទី៨ ខិតខំរៀបចំបានយ៉ាងល្អឥតខ្ចោះ

. តាមសាវតាក្រសួងអប់រំ យុវជន និងកីឡា រៀបចំទិវាជាតិអំណាន បាន៧លើករួចមកហើយ ចាប់តាំងពីឆ្នាំ ២០១៦។

. ឆ្នាំ២០២៣នេះ ជាការរៀបចំទិវាជាតិអំណានលើកទី៨ ស្ថិតក្រោមប្រធានបទ " *អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ* "។ ការរៀបចំទិវាជាតិអំណាន គឺជាការធ្វើឱ្យរស់ឡើងវិញ នូវការថែរក្សាវប្បធម៌ និងអរិយធម៌ជាតិ ដោយការបណ្តុះអានផង និងសរសេរតែងនិពន្ធផង។

. ការជ្រើសយកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ ជាថ្ងៃខួបកំណើតរបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត** ព្រះអង្គខិតខំរក្សាអក្សរសាស្ត្រជាតិ វប្បធម៌ជាតិ និងបានបង្កើតវចនានុក្រម ជួន ណាត សម្រាប់យើងទាំងអស់គ្នា។

. ការរៀបចំកម្មវិធីប្រឡងប្រណាំងនេះឡើង ជាគំនិតផ្តួចផ្តើមរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ដើម្បីឱ្យដំណើរការប្រារព្ធទិវាជាតិអំណាន មានភាពអធិកអធម និងបានទូលំទូលាយ ហើយក៏ជាការផ្សារភ្ជាប់ជំនាន់មនុស្ស ព្រមទាំងអ្នកចូលរួមបានសប្បាយរីករាយ ញញឹមរីករាយរកគ្នាប្រកបដោយវប្បធម៌ឆ្លើយតបដោយវិជ្ជមាន។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការ** បានសំណូមពរដល់គណៈកម្មការវាយតម្លៃដាក់ពិន្ទុសូមកុំលម្អៀង និងបានប្រកាសបើកកម្មវិធីប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី អាន ស្មូត និងតែងនិពន្ធ។

**គ.៣ ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី**

ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីលេខ១ លេខ២ លេខ៣ ផ្នែកអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ សម្រាប់ទទួល "**ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន**" និងបកស្រាយប្រធានបទ ស្តីពី "*គុណតម្លៃមនុស្ស ក្នុងយុគសម័យឌីជីថល*" បានប្រព្រឹត្តទៅតាមពេលវេលា ទីកន្លែង សកម្មភាព និងលទ្ធផលដូចខាងក្រោម៖

**១.ការប្រឡងប្រណាំង អាន**

បានប្រព្រឹត្តទៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ នៅសាលប្រជុំនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មានខ្លឹមសារ និងសកម្មភាព៖



**១.១** គណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡង អានអត្ថបទ

| | | | |
|---|---|---|---|
| ១. ល. | **ឃឹម សារិន** | អនុប្រនា.អកស | ប្រធាន |
| ២. ល. | **យ៉ង់ កំស៊ាន** | ប្រ.កាវិ.នា.អកស | អនុប្រធាន |
| ៣. ល. | **យូ លក្ខិណា** | អនុប្រ.កាវិ.នា.អកស | សមាជិក |
| ៤. ល.ស. | **ផាន់ សុជាតា** | មន្ត្រីនា.អកស | សមាជិក |
| ៥. ល. | **ទិត សុខខេង** | មន្ត្រីនា.អកស | សមាជិក |
| ៦. ល. | **ព ឆ្វយ** | មន្ត្រី នា.អកស | លេខាធិការ |

**១.២** បេក្ខជនចូលរួមប្រឡងប្រណាំង



បេក្ខជនទាំងអស់មកពី២៥ រាជធានី ខេត្ត សរុបមាន ២៥នាក់ ក្នុងនោះស្រី២៣នាក់ ជាសិស្សកំពុងសិក្សានៅថ្នាក់ទី៤,៥,៦ នៃសាលាបឋមសិក្សាចំណោះទូទៅ(រូបភាពទី១)។

១.៣ សកម្មភាពវាយតម្លៃដាក់ពិន្ទុ

ក្នុងការវាយតម្លៃដាក់ពិន្ទុ គណៈកម្មការបានឱ្យបេក្ខជនឡើងអានអត្ថបទ ដែលបានរៀបចំរួចជាស្រេចរៀងៗខ្លួនម្តងម្នាក់ៗ ដោយសមាជិកគណៈកម្មការម្នាក់ៗ បានវាយតម្លៃដាក់ពិន្ទុរៀងៗខ្លួន និងយកពិន្ទុដែលបានវាយតម្លៃនោះមកសរុបរកមធ្យមភាគសម្រាប់ជ្រើសរើសកំណត់បេក្ខជនជ័យលាភី។

**២.ការប្រឡងប្រណាំង ស្មូតកំណាព្យ**

បានប្រព្រឹត្តទៅនាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ នៅសាលប្រជុំជាន់ទី១ អគាររដ្ឋបាលថ្មីក្រសួងអប់រំ យុវជន និងកីឡា មានខ្លឹមសារ សកម្មភាព និងលទ្ធផលដូចខាងក្រោម ៖

២.១ សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ



១.ល.ជទ. បណ្ឌិត**សឿ សុជាតា** អនុរដ្ឋ.ក្រសួងអយក.ប្រធាន
២. ល.ជទ. **ឃុន រចនា** អនុរដ្ឋ.ក្រសួងអយក. អនុប្រ.
៣. ឯ.ឧ. **យ៉ាន់ មុរិន** ទីប្រឹក្សាក្រសួងវប្ប.វិចិត្រសិល្បៈ អនុប្រ.
៤. ល.ស **ម៉ៅ តាន់ណាទី** អនុប្រ.កា.វិ នា.អកស. សមាជិក
៥. ល. **ខិន សុគារា** អនុប្រ.កា.វិ. នា.អកស. សមាជិក
៦. ល. **ហ៊ុន ឡាច** មន្ត្រី. នា.អកស. លេខាធិការ

**២.២** បេក្ខជនទាំងអស់មកពី ២៥ រាជធានី ខេត្ត សរុបមាន ២៥នាក់/ស្រី២១នាក់ ជាសិស្សរៀនថ្នាក់ទី៧,៨,៩ នៃសាលាមធ្យមសិក្សាចំណេះទូទៅ (រូបភាពទី២)។

**២.៣** សកម្មភាពវាយតម្លៃដាក់ពិន្ទុ



ក្នុងការវាយតម្លៃដាក់ពិន្ទុ គណៈកម្មការវាយតម្លៃ បានឱ្យបេក្ខជនឡើងសូត្រកំណាព្យម្តងម្នាក់ៗ តាមលំនាំនិងខ្លឹមសារបទ ដែលបេក្ខជនបានរៀបចំរួចជាស្រេចរៀងៗខ្លួន ដោយសមាជិកគណៈកម្មការម្នាក់ៗ បានវាយតម្លៃដាក់ពិន្ទុរៀងៗខ្លួនលើបេក្ខជនម្នាក់ៗ និងយកពិន្ទុនោះមកសរុបរួមរកមធ្យមភាគសម្រាប់ជ្រើសរើសកំណត់បេក្ខជនជ័យលាភី។

**៣.ការប្រឡងប្រណាំង តែងនិពន្ធ**

បានប្រព្រឹត្តទៅនាថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ នៅមជ្ឈមណ្ឌលឯកសារនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាជាន់ទី៦ នៃអគាររដ្ឋបាលថ្មីក្រសួងអប់រំ យុវជន និងកីឡា មានខ្លឹមសារ សកម្មភាព និងលទ្ធផលដូចខាងក្រោម ៖

**៣.១** សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំងតែងនិពន្ធ



១. ឯ.ឧ **ជ័យ ចាប** ទីប្រឹក្សារាជរដ្ឋាភិបាល ប្រធាន
២.ល.ជទ **ទន់ សាអ៊ីម** អនុរដ្ឋ.ក្រសួងអយក. អនុប្រធាន
៣. ល. **យិន ធី** អនុប្រ.នា.អកស. សមាជិក
៤. ល.ស **ណាត ស៊ីវឡាយ** អនុប្រ.កា.វិ.នា.មចទ. សមាជិក
៥. ល. **ព្រៃ សំបូរ** អនុប្រ.កា.វិ.នា.អកស. សមាជិក
៦. ល. **ដាំ បេខ** មន្ត្រីនា.អកស. លេខាធិការ

**៣.២** បេក្ខជនចូលរួមប្រឡងប្រណាំង

បេក្ខជនមកពី ២៥រាជធានី ខេត្ត សរុបមាន ២៥នាក់ ក្នុងនោះស្រី ១៩នាក់ ជាសិស្សរៀននៅថ្នាក់ទី១០,១១ និង១២ នៃវិទ្យាល័យចំណេះទូទៅ (រូបភាពទី៣)។

**៣.៣** សកម្មភាពវាយតម្លៃដាក់ពិន្ទុ



ក្នុងការវាយតម្លៃដាក់ពិន្ទុ គណៈកម្មការបានរៀបចំឱ្យបេក្ខជនចូលប្រឡងក្នុងមជ្ឈមណ្ឌលឯកសារ ដោយអង្គុយរក្សាគម្លាតសុវត្ថិភាព និង ដំណើរការប្រឡងស្ថិតក្រោមការត្រួតពិនិត្យ និងកែដាក់ពិន្ទុ ពីគណៈកម្មការវាយតម្លៃដាក់ពិន្ទុសម្រាប់ជ្រើសរើសកំណត់បេក្ខជនជ័យលាភី។

**៤.ការប្រឡងប្រណាំងបកស្រាយប្រធានបទ**

**៤.១** សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំងបកស្រាយប្រធានបទ

១.ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ម៉ិនឡឿន** រដ្ឋលេខាធិការក្រសួង.អយក. ប្រធាន



២. ល.ជទ. **ទន់ សារ៉ឹម** អនុរដ្ឋ.ក្រសួងអយក. អនុប្រធាន

៣. ល.ជទ បណ្ឌិត **ឃួន វិចិត្រា** អគ្គ.រង.រប.ហវ. សមាជិក

៤. ល. **យិន ធី** អនុប្រ.នា.អកស. សមាជិក

៥. ល. **ទ្រៀ សំបូរ** អនុប្រ.ការិ.នា.អកស. សមាជិក

៦. ល. **សុខ បញ្ញាវឌ្ឍន៍** មន្ត្រីនា.អកស. លេខាធិការ

**៤.២** បេក្ខជនចូលរួមប្រឡងប្រណាំង

បេក្ខជនសរុប ២៥នាក់ ក្នុងនោះស្រីមាន ២នាក់ ជាគ្រូបង្រៀន អ្នកសារព័ត៌មាននិងនិស្សិតមកពី៩ រាជធានីខេត្ត(រូបភាពទី៤)

៤.៣ សកម្មភាពវាយតម្លៃដាក់ពិន្ទុ

ការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំងបកស្រាយប្រធានបទ ត្រូវបានគណៈកម្មការរៀបចំជាពីរដំណាក់កាល គឺលើកទី១ធ្វើនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ សាលប្រជុំរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ជ្រើសរើសយកអ្នកដែលមានពិន្ទុខ្ពស់ ១០នាក់ក្នុងចំណោម១៥នាក់ និងលើកទី២ធ្វើនៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ដើម្បីជ្រើសរើសយកបេក្ខជនជ័យលាភី ៣នាក់ក្នុងចំណោម ១០នាក់។

**ឃ. ការប្រកាសលទ្ធផលប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ**

ថ្ងៃទី១០ ខែ មីនា ឆ្នាំ២០២៣ វេលាម៉ោង ៨:៣០ នាទី នៅសាលប្រជុំជាន់ទី១ អគាររដ្ឋបាលថ្មីក្រសួងអប់រំ យុវជន និងកីឡា មានរៀបចំពិធីប្រកាសលទ្ធផលជ័យលាភីថ្នាក់ជាតិការប្រឡងប្រណាំង អានអត្ថបទ ស្លូតកំណាព្យ និងតែងនិពន្ធ។ ពិធីនេះ ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ទន់ សារ៉ឹម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ជាតំណាងដ៏ខ្ពង់ខ្ពស់បំផុត ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី និងជាអនុប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំង** ព្រមទាំងការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំង អានអត្ថបទ ស្លូតកំណាព្យ និងតែងនិពន្ធ បេក្ខជន ប្រតិភូដឹកនាំតាមរាជធានី ខេត្ត និងអ្នកអាណាព្យាបាលបេក្ខជនសរុបប្រមាណ ២០០នាក់។

**ឃ.១** របាយការណ៍សកម្មភាពការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី

លោក **យិន ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាបានបង្ហាញជូនអង្គពិធីថា ការប្រឡងប្រណាំង



ជ្រើសរើសបេក្ខជនជ័យលាភី អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ បានចាប់ផ្ដើមពីថ្ងៃទី ០៨ ដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ ២០២៣ ដោយមានបេក្ខជនមកពីរាជធានី ខេត្ត ៧៥ នាក់/ស្រី ៦៤ នាក់ បានប្រព្រឹត្តទៅដោយរលូន និងម៉ត់ចត់បំផុតដោយទទួលបានបេក្ខជនជ័យលាភី៩ នាក់ក្នុងនោះ អានអត្ថបទ ៣ នាក់ ស្មូតកំណាព្យ៣នាក់ និងតែងនិពន្ធ ៣នាក់។

**ឃ.២** របាយការណ៍ផ្នែកអានអត្ថបទ

លោក **យឹម សារិន** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងជាប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំងអានអត្ថបទ មានប្រសាសន៍ថា លទ្ធផលនៃការអានអត្ថបទរបស់បេក្ខជនមានការរីកចម្រើនគួរឱ្យកត់សម្គាល់ប្រសិនបើប្រៀបធៀបនឹងការប្រឡងប្រណាំងផ្នែកអំណានឆ្នាំកន្លងផុតមុនៗ ដោយឡែកផ្នែកសំនៀង (សំឡេង) និងការដកឃ្លា នៅមានកំហុសច្រើន។

**ឃ.៣** របាយការណ៍ផ្នែកតែងនិពន្ធ



លោក **ព្រៃ សំបូរ** អនុប្រធានការិយាល័យ និងជាសមាជិកនៃគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រណាំងតែងនិពន្ធ បង្ហាញថា ៖

. ការនិពន្ធ ផ្នែកអត្ថន័យ និងជើងកាព្យ ធ្វើបានល្អ ដែលបានឆ្លុះបញ្ចាំងឱ្យឃើញពីការរីកចម្រើននៃការបង្រៀន របស់លោកគ្រូ អ្នកគ្រូ នៅតាមសាលារៀន។

. គណៈកម្មការបានលើកយកខ្លឹមសារ និងជើងកាព្យ មកធ្វើជាចំណុចសំខាន់ក្នុងការវាយតម្លៃដាក់ពិន្ទុ។

**ឃ.៤** របាយការណ៍ផ្នែកស្មូតកំណាព្យ



លោកជំទាវបណ្ឌិត **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡានិង ជាប្រធានគណៈកម្មការវាយតម្លៃដាក់ពិន្ទុប្រឡងប្រណាំងផ្នែកស្មូតកំណាព្យមានប្រសាសន៍ដូចខាងក្រោម ៖

. ការគោរពអរគុណដល់ ឯកឧត្ដមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី ដែលបានផ្ដួចផ្ដើម ឱ្យមានកម្មវិធីប្រឡងប្រណាំងនេះឡើង ដើម្បីបណ្ដុះបណ្ដាលផ្នែកកំណាព្យដល់មនុស្សជំនាន់ក្រោយ

. កោតសរសើរដល់អ្នកចូលរួមទាំងអស់ដែលបានគោរពវិន័យ មានរបៀបរៀបរយ មានសណ្ដាប់ធ្នាប់ ក្នុងពេលដំណើរការប្រឡងប្រណាំង

. គណៈកម្មការមានការស្មុគស្មាញក្នុងការវាយតម្លៃដាក់ពិន្ទុ ព្រោះលទ្ធផលបេក្ខជនប្រហាក់ប្រហែលគ្នា

. ការវាយតម្លៃដាក់ពិន្ទុគណៈកម្មការបានវាយតម្លៃផ្អែកតាមលំនាំស្មូតកំណាព្យរបស់**ឯកឧត្ដម យ៉ាន់ ម៉ូរិន ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** ដែលមានការទទួលស្គាល់ពីរាជបណ្ឌិត្យសភាកម្ពុជា។

**ឃ.៥** ប្រសាសន៍បិទបញ្ចប់ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ



**លោកជំទាវ ឆន់ សារ៉ុម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា** មានប្រសាសន៍ដូចខាងក្រោម ៖

. ដំណើរការប្រឡងប្រណាំងអាន ស្នូតកំណាព្យ និងតែងនិពន្ធ យើងបានចាប់ផ្ដើមតាំងពីរខែមុនមក ដោយធ្វើការប្រឡងប្រណាំងជ្រើសរើសបេក្ខជន តាមរាជធានី ខេត្ត

. ការរៀបចំប្រឡងប្រណាំង និងការទទួលបានលទ្ធផលថ្ងៃនេះ គឺយើងបានរកឃើញអ្នកបន្តវេន ថែរក្សាការពារ និងអភិរក្សសម្បត្តិវប្បធម៌ បូរណភាពទឹកដី។

. អំណានកម្រិតបឋមសិក្សា ជាមូលដ្ឋានគ្រឹះសម្រាប់បន្តការសិក្សាទៅផ្នែកដទៃៗទៀត

. ប្រតិភូ រាជធានី ខេត្តត្រូវយកចិត្តទុកដាក់លើអំណានដំបូង ដូចជា ការបន្លឺពាក្យឱ្យបានត្រឹមត្រូវ ចំៗ មិនបន្លំពាក្យ ការប្រើពាក្យកុំឱ្យខុស គឺចំតាមអក្ខរាវិរុទ្ធ

. ការស្នូតកំណាព្យបានពិរោះល្អ និងសូមរក្សាភាពត្រឹមត្រូវនេះឱ្យបានល្អខ្ជាប់ខ្ជួន ព្រោះជាស្នាដៃរបស់ខ្មែរ

. ការតែងនិពន្ធ ការចូលរួមគួរមានសមភាពយេនឌ័រព្រោះបេក្ខជនសរុប ២៥នាក់/ស្រីមានដល់១៩ នាក់។

ជារួម បេក្ខជនជាជ័យលាភីមកពីតាមរាជធានី ខេត្ត សុទ្ធតែល្អៗ ដែលជាហេតុនាំឱ្យគណៈកម្មការវាយតម្លៃពិបាកវិនិច្ឆ័យ ព្រោះលទ្ធផលរបស់បេក្ខជនមានលក្ខណៈប្រហាក់ប្រហែលគ្នា។

## ការប្រកាសលទ្ធផលជ័យលាភី

### ក.ជ័យលាភីផ្នែក អានអត្ថបទ




. ចំណាត់ថ្នាក់លេខ៣ កុមារី **ស៊ឹម ស្រីលក្ខណ៍** សិស្សសាលាបឋមសិក្សា ណាមីកូភ្នំសសៀរ ខេត្តកែប

. ចំណាត់ថ្នាក់លេខ២ កុមារី **សៅ ឆេងហួយ** សិស្សសាលាបឋមសិក្សា ក្អិន ខេត្តកំពង់ធំ

. ចំណាត់ថ្នាក់លេខ១ កុមារី **លេខា សៀវម៉ី** សិស្សសាលាបឋមសិក្សា ប៊ុនរ៉ានីហ៊ុនសែនអនុវត្ត ខេត្តកណ្ដាល

### ខ.ជ័យលាភីផ្នែក ស្នូតកំណាព្យ




. ចំណាត់ថ្នាក់លេខ៣ កុមារា **សំរេច រួន** សិស្ស អនុវិ. ពោធិ៍វង្ស ខេត្តឧត្ដរមានជ័យ

. ចំណាត់ថ្នាក់លេខ២ កុមារា **នៅ កោសល្យ** សិស្ស វិ.ហស. បុរី១០០ខ្នង រាជធានីភ្នំពេញ

. ចំណាត់ថ្នាក់លេខ១ កុមារី **សាត់ ស្រីណុច** សិស្ស វិ. សម្ដេចឪសម្ដេចម៉ែ បរសេដ្ឋ ខេត្តកំពង់ស្ពឺ

### គ.ជ័យលាភីផ្នែក តែងនិពន្ធ




. ចំណាត់ថ្នាក់លេខ៣ យុវជន **សុភាជ វិសិដ្ឋ** សិស្ស វិទ្យាល័យមេសាង ខេត្តព្រៃវែង

. ចំណាត់ថ្នាក់លេខ២ យុវតី **អ៊ឹម អែម** សិស្ស វិទ្យាល័យកំពង់ធំ ខេត្តកំពង់ធំ

. ចំណាត់ថ្នាក់លេខ១ យុវតី **យឹម សូនីតា** សិស្ស វិទ្យាល័យសម្តេចតេជោ ហ៊ុនសែន រលាំងឈូក ខេត្តកំពង់ស្ពឺ

### ឃ.ជ័យលាភីផ្នែក បកស្រាយប្រធានបទ

. លេខ៣ លោក **ទឹម សុខហួយ** គ្រូបង្រៀន វិ.សម្តេចអគ្គមហាសេនាបតីតេជោហស.អង្គតាសោម ខេត្តតាកែវ

. លេខ២ លោក **មិន ម៉ៅសំណាង** អ្នកសារព័ត៌មាន ស្ថានីយ៍ទូរទស្សន៍ ភី.អិន.អិន

. លេខ១ លោក **ម៉ី សុវណ្ណ** គ្រូបង្រៀន វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

លោកជំទាវអនុរដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី បានកោតសរសើរដល់គណៈកម្មការវាយតម្លៃដាក់ពិន្ទុទាំងអស់ ដែលបានយកចិត្តទុកដាក់ និងណែនាំជួយកែតម្រូវចំណុចខ្វះខាត ជូនដល់បេក្ខជន និងសូមឱ្យបេក្ខជនដែលមិនបានទទួលជ័យលាភី កុំបោះបង់ការប្រឡងប្រណាំង ព្រោះការប្រឡងប្រណាំងបានបង្ហាញពីសមត្ថភាពរបស់យើងផ្ទាល់ និងទទួលបានបទពិសោធន៍នៅក្នុងការប្រឡងនេះ។

លោកជំទាវអនុរដ្ឋលេខាធិការ បានអំពាវនាវសូមចូលរួមទស្សនាពិព័រណ៍សៀវភៅឱ្យបានគ្រប់គ្នា សៀវភៅជាមិត្តដ៏ល្អ ជាគ្រូបង្រៀន និងជួយឱ្យយើងបំបាត់ការអផ្សុក។

## ៣.សកម្មភាពស្តង់តាំងពិព័រណ៍សៀវភៅអបអរសាទរទិវាជាតិអំណានលើកទី៨

### ក.ការសម្ពោធស្តង់តាំងពិព័រណ៍សៀវភៅ



ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានរៀបចំសម្ពោធស្តង់តាំងពិព័រណ៍សៀវភៅចំនួន ១១០ស្តង់ មាន៨៧ក្រុមហ៊ុន ដែលស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួង អង្គភាពថ្នាក់កណ្តាល និងក្រុមយុវជនស្ម័គ្រចិត្ត ប្រមាណ១០០ នាក់។ ការរៀបចំសម្ពោធស្តង់តាំងពិព័រណ៍សៀវភៅនេះ មានគោលបំណង៖




. អបអរសាទរការប្រារព្ធពិធីទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣

. ថែរក្សាអភិរក្សវប្បធម៌ អរិយធម៌ និងអក្សរសាស្ត្រខ្មែរ និងការផ្សារភ្ជាប់ជំនាន់មនុស្ស

. ផ្សព្វផ្សាយដល់គ្រប់ស្រទាប់មហាជន ពីសមិទ្ធិផលជាស្នាដៃ របស់អ្នកករនិពន្ធទាំងកម្រិតជាតិ និងអន្តរជាតិ ទាំងបរិមាណ និងគុណភាពសៀវភៅ ព្រមទាំងការរួមទស្សនា និងជាវសៀវភៅតាមចំណង់ចំណូលចិត្ត និងតម្រូវការ។

**ខ. សកម្មភាព និងលទ្ធផលស្តង់តាំងពិព័រណ៍សៀវភៅ**

ការតាំងស្តង់ពិព័រណ៍សៀវភៅបានប្រព្រឹត្តទៅមានរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ ២០២៣ ដើម្បីអបអរសាទរទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣។ ក្នុងរយៈពេល៣ថ្ងៃនេះ មានអ្នកចូលរួមជាសិស្សានុសិស្ស និស្សិត និងមហាជន សរុបជិត៣០០០០នាក់( សម្រង់ព័ត៌មាន តាមក្រុមយុវជនស្ម័គ្រចិត្ត )។

សកម្មភាពចូលរួមទស្សនាស្តង់ពិព័រណ៍សៀវភៅរបស់មហាជន រួមមាន ៖

. ការមើលសៀវភៅ និងរកជាវសៀវភៅតាមតម្រូវការជាក់ស្តែង ដែលពួកគាត់ចូលចិត្តមានដូចជា សៀវភៅអប់រំចិត្ត សៀវភៅអានបន្ថែម សៀវភៅសម្រាប់កុមារ សៀវភៅមានលក្ខណៈបច្ចេកទេសជំនាញ

. ការទស្សនា និងចូលរួម ការគូរគំនូរផាត់ពណ៌របស់កុមារ

. ការថតកំសាន្តសប្បាយ នៅស្តង់ថតរូប និងមើលការប្រគុំតន្ត្រី

. ការជួបជុំមិត្តភក្តិ ការមើល និងជាវសៀវភៅ និងការវិលត្រឡប់វិញជាមួយនឹងកញ្ចប់សៀវភៅ។

**៤. សិក្ខាសាលា ស្តីពី " ការអភិវឌ្ឍបណ្ណាល័យសាលារៀន "**




ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង១៤:០០នាទី នៅសាលសន្និសីទA នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានរៀបចំសិក្ខាសាលា ស្តីពី "*ការអភិវឌ្ឍបណ្ណាល័យសាលារៀន* "។ សិក្ខាសាលា បានស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិត ស្មើ សុជាតា អនុរដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់** ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួង អង្គភាពក្រោមឱវាទទីស្តីការក្រសួង ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុងស្រុកខណ្ឌ គណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូ សរុបប្រមាណ៥០០នាក់។

**ក.សុន្ទរកថាបើកសិក្ខាសាលា**



ប្រសាសន៍បើកសិក្ខាសាលាដោយ **លោកជំទាវបណ្ឌិត ស្មើ សុជាតា អនុរដ្ឋលេខាធិការ** មានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម ៖

. ការគោរពអរគុណ និងកោតសរសើរដល់ថ្នាក់ដឹកនាំ និងមន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ថ្នាក់ដឹកនាំនិងមន្ត្រី មកពីរាជធានី ខេត្ត ពិសេសអង្គការរូមធូរីដដែលបានសហការយកចិត្តទុកដាក់ និងចូលរួមរៀបចំអបអរសាទរទិវាជាតិអំណានលើកទី៨

. ជោគជ័យនៃដំណើរការកំណែទម្រង់វិស័យអប់រំ បានមកពីការសហការចូលរួមពីមន្ត្រីអប់រំគ្រប់រូប និងអង្គ

ការដៃគូអភិវឌ្ឍ

. សារៈសំខាន់ និងតួនាទីរបស់បណ្ណាល័យ ជាចលករ ជាឃ្លាំងធនធានចំណេះដឹងដ៏សម្បូរបែប និងធំបំផុតសម្រាប់ជួយដល់អ្នកសិក្សា និងអ្នកអានទាំងអស់ ទាំងមេរៀនពិសោធន៍ពេលបច្ចុប្បន្ន និងអនាគត

. ការអភិវឌ្ឍបណ្ណាល័យ ជាមូលដ្ឋានគ្រឹះមួយយ៉ាងសំខាន់ ដែលកន្លងមកមានអង្គការដៃគូជួយអភិវឌ្ឍ និងកែលម្អទំនើបកម្ម។

ជារួម សិក្ខាសាលានេះ អ្នកចូលរួមទាំងអស់នឹងយល់ដឹងពី ការអភិវឌ្ឍបណ្ណាល័យសាលារៀន និងដំណើរការរៀបចំទិវាជាតិអំណាន។ លោកជំទាវបានអរគុណដល់ដៃគូអភិវឌ្ឍ រាជរដ្ឋាភិបាលដែលបានកសាងបណ្ណាល័យជូនដល់សាលារៀន។

**ខ. បទបង្ហាញរបស់អង្គការ Room to Read**

លោក **ហោ សុខ:** នាយកកម្មវិធីអំណានអង្គការ រូមធូរីដ បានធ្វើបទបង្ហាញស្តីពី "អានុភាពនៃបណ្ណាល័យ និងអំណានឮ " មានខ្លឹមសារសំខាន់ៗដូចខាងក្រោម ៖

. តំបន់ប្រតិបត្តិការរបស់អង្គការមាន២១ប្រទេសដោយឡែកក្នុងកម្ពុជាមាន ខេត្តកំពង់ស្ពឺ កំពង់ចាម ព្រៃវែង កំពង់ធំ សៀមរាប និងបាត់ដំបង។

**តួនាទីរបស់បណ្ណាល័យសាលាបឋមសិក្សា**

. ជាកន្លែងអាន ស្វែងរកស្រាវជ្រាវ រិះគិត បង្កើតក្តីស្រមៃនិងការច្នៃប្រឌិត ដែលនេះជាមូលដ្ឋាននៃការសិក្សាស្វែងយល់ និងពង្រឹងបន្ថែមនូវព័ត៌មានផ្ទាល់ខ្លួន សង្គម និងវប្បធម៌របស់សិស្សានុសិស្ស

. ផ្តល់នូវបំណិនអានស៊ីជម្រៅ អភិវឌ្ឍបំណិននិយាយ បំណិនទំនាក់ទំនង និងសហការបានបន្តការរៀនសូត្របន្ថែម ក្តីស្រឡាញ់ និងទម្លាប់

. ផ្តល់នូវសៀវភៅច្រើនបែបសម្រាប់កុមារអាននិងខ្ចីអាននៅផ្ទះ គ្រូដឹកនាំ និងណែនាំការអានរបស់សិស្ស

. អំណានឮនិងការជជែកអំពីសាច់រឿង បានជួយសម្រួចខួរក្បាលកុមារកាន់តែមុតស្រួច បង្កើនសមត្ថភាពផ្ចង់អារម្មណ៍ ចងចាំបានយូរ អាចចេះដោះស្រាយបញ្ហាបានជាក់លាក់ និងអាចបង្ហាញប្រាប់គេពីអ្វី ដែលចង់ប្រាប់គេបានយ៉ាងងាយស្រួល

. កុមារបានអាន បានគិត បាននិយាយ នឹងនាំឱ្យកុមារចេះប្រើភាសា ចេះទំនាក់ទំនង និងបង្កើនទំនុកចិត្តឱ្យអាចអានបានពេញមួយជីវិត។

**សារៈសំខាន់របស់សៀវភៅ**

. អ្នករៀនភាសាកំណើតក៏ដូចជាភាសាទី២ដំបូងដែរ ពួកគាត់ចេះពាក្យ អាចទំនាក់ទំនងក្នុងសង្គមដោយសារបានស្តាប់ បានគិត ពិសេសបានអានសៀវភៅ

. ការអាន បានធ្វើឱ្យកុមារមានបំណិនសង្គមបានប្រសើរ បង្កើនទំនុកចិត្ត និងបានកាត់បន្ថយនូវអាកប្បកិរិយាមិនសមរម្យនៅសាលារៀន និងនៅផ្ទះ ចេះផ្សារភ្ជាប់ជីវិតរបស់កុមារជាមួយនឹងជីវិតអ្នកដទៃ

. សៀវភៅនៅតែជាមូលដ្ឋាននៃការអភិវឌ្ឍចំណេះដឹង និងការសរសេរសៀវភៅបានល្អគឺត្រូវមានចំណេះដឹងទូលំទូលាយ និងត្រូវសរសេរអ្វីដែលនៅជុំវិញខ្លួន ។

**សកម្មភាពជួយកុមារ**

. ការរៀនអាន ទាមទារការបង្រៀនមួយដែលនាំកុមារឱ្យជក់ចិត្ត និងចងចាំនូវបទពិសោធន៍មួយដ៏រីករាយ

. ការជួយកុមារឱ្យធាប់ចេះសរសេរ គឺផ្តោតលើគំរូសំណេរល្អៗ និងជម្រៅនៃខ្លឹមសារសំណេរ
. ការជួយកុមារឱ្យអាននៅផ្ទះបានល្អ គឺគួរតែជ្រើសរើសខ្ចីយកសៀវភៅដែលគ្រូបានយកមកអានឱ្យកុមារបានឃើញនៅបណ្ណាល័យ
. បណ្ណាល័យបឋមសិក្សា ខុសពីបណ្ណាល័យទូទៅ ដោយបណ្ណាល័យបឋមសិក្សា បំណងធំសំខាន់គឺ បង្កើនទម្លាប់ការអានរបស់កុមារ។

**គ. បទបង្ហាញ ស្តីពី " ការរៀបចំទិវាជាតិអំណាន "**



លោក **ម៉ុក វ៉ាស៊ី ប្រធានបណ្ណាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវ** បានបង្ហាញពីដំណើរការរៀបចំទិវាជាតិអំណាន ដែលមានខ្លឹមសារដូចខាងក្រោម ៖

. ការកំណត់ Logo ទិវាជាតិអំណាន
.ការរៀបចំប្រារព្ធពិធីទិវាជាតិអំណានតាំងពីឆ្នាំ២០១៦មកម្ល៉េះ ដែលដំបូងមានអ្នកចូលរួមតែ១៦៨៣ នាក់
.ការប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភី ផ្នែកអាន ស្មូតកំណាព្យ និងតែងនិពន្ធ មិនសំដៅតែសិស្សសាលារដ្ឋទេ គឺសាលារៀនចំណេះទូទៅទាំងអស់ត្រូវបានអនុញ្ញាតឱ្យចូលរួម
. ការប្រឡងប្រណាំងអាន ផ្តោតទៅលើការជ្រើសរើសយកសិស្សផ្នែកបឋមសិក្សា ការស្មូតកំណាព្យ ផ្តោតលើសិស្សអនុវិទ្យាល័យ និងការតែងនិពន្ធសំដៅលើសិស្សវិទ្យាល័យ
. ការបង្ហាញពីសមាសភាពត្រូវចូលរួមក្នុងកម្មវិធីប្រារព្ធទិវាជាតិអំណាន
. លំនាំនៃដំណើរការរៀបចំទិវាជាតិអំណាន ក្រសួងបានរៀបចំសេចក្តីជូនដំណឹងដល់រាជធានី ខេត្ត ដើម្បីអនុវត្ត និងដឹកនាំការងារប្រឡងប្រណាំងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់រាជធានី ខេត្ត និងការរៀបចំអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញមន្ទីរអញ្ជើញចូលរួមក្នុងកម្មវិធីការប្រារព្ធទិវាជាតិ។

## ៥.ការប្រារព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣

### *៥.១ កម្មវិធីពេលព្រឹក*



ការប្រារព្ធទិវាជាតិអំណានលើកទី៨ បានប្រព្រឹត្តទៅនាថ្ងៃសៅរ៍ ៥រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ ក្រោមប្រធានបទ " ***អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ*** " នៅសាលប្រជុំវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ អង្គពិធី បានស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយ**

រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី **នៃព្រះរាជាណាចក្រកម្ពុជា** និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ លោក លោកស្រី ជាថ្នាក់ដឹកនាំមន្ទីរ អង្គភាពមកពី២៥ រាជធានី-ខេត្ត ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ និងមន្ត្រីអប់រំ សរុប ២៦០១នាក់។ បន្ទាប់ពីបានគោរពទង់ជាតិ និងបទពង្សាវតាខ្មែររួចមក អង្គពិធីបានដំណើរការតាមរបៀបវារៈ និងមានខ្លឹមសារដូចខាងក្រោម៖

*ក. របាយការណ៍វឌ្ឍនភាព ស្តីពី " ការរៀបចំទិវាជាតិអំណានចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២ "*

**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ធ្វើរបាយការណ៍ជូន សម្តេចកិត្តិសង្គហបណ្ឌិត និងអង្គពិធីដោយមានខ្លឹមសារដូចខាងក្រោម៖

. ការគោរពកិច្ចស្វាគមន៍យ៉ាងកក់ក្តៅបំផុត ចំពោះវត្តមានដ៏ឧត្តុងឧត្តមរបស់ សម្តេចកិត្តិសង្គហបណ្ឌិត



ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងការប្រារព្ធទិវាជាតិអំណានលើកទី៨ ១១មីនា ២០២៣ ក្រោមប្រធានបទ" *អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ* " នាពេលនេះ

. ការថ្លែងអរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ដែលបានចូលរួមដោយផ្ទាល់ និងការទស្សនាតាមអនឡាញ ក្នុងទិវាជាតិអំណានលើកទី៨

. ការបង្ហាញពីគោលបំណងនៃការប្រារព្ធទិវាជាតិអំណាន ដើម្បីរំលឹកដល់វីរៈភាព និងគុណូបការៈដ៏ថ្លៃថ្លារបស់សម្តេចព្រះសង្ឃរាជ**ជួន ណាត** ក្នុងការពុះពារការពារមរតកវប្បធម៌ អក្សរសាស្ត្រខ្មែរនិងការបណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ ព្រមទាំងពង្រីកចំណេះដឹងដល់ពលរដ្ឋកម្ពុជាគ្រប់រូប។

. ក្រសួងបានជ្រើសរើសយកសៀវភៅ អរិយធម៌ វប្បធម៌ និងប្រជុំរឿងព្រេងខ្មែរ ឱ្យសិស្សអានបន្ថែមដើម្បីលើកកំពស់ចំណេះដឹងវប្បធម៌ និងអរិយធម៌ខ្មែរ

. ក្រសួងនឹងចេញសេចក្តីណែនាំដល់សាលារៀនទាំងអស់ ឱ្យរៀបចំលេងល្បែងប្រពៃណីនៅក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ ដើម្បីសិស្សានុសិស្សបានយល់ដឹងពីរបាំ និងល្បែងប្រពៃណី ដូចជា បោះអង្គុញ ចោលឈូង និងលាក់កន្សែង។ល។

. អំណានជាមូលដ្ឋានគ្រឹះនៃការទទួលបានចំណេះដឹងនិងជាគន្លឹះដើម្បីពង្រឹងគុណភាពអប់រំ ដើម្បីឱ្យកុមារ និងយុវជនកម្ពុជា មានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា ក្លាយជាពលរដ្ឋល្អក្នុងសង្គម

. ចាប់ពីឆ្នាំ២០១៨ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍរៀបចំវិធីសាស្ត្រទំនើបក្នុងការបង្រៀន ភាសាខ្មែរ ថ្នាក់ទី១,២និងទី៣ និងផលិតកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូងមុខវិជ្ជាភាសាខ្មែរ (៣០ចំណងជើង) និងកញ្ចប់សម្ភារៈគណិតវិទ្យា ថ្នាក់ដំបូងសម្រាប់បម្រើការបង្រៀន និងរៀន និងការបណ្តុះបណ្តាលគ្រូនៅទូទាំងប្រទេស និងបានដាក់បញ្ចូលកញ្ចប់អំណានទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូផងដែរ

. អង្គការភាពជាដៃគូសកលដើម្បីការអប់រំ បានយកប្រទេសកម្ពុជាជាប្រទេសគម្រូក្នុងការបណ្តុះបណ្តាល

គ្រូ នៅក្នុងតំបន់អាស៊ីប៉ាស៊ីភិច

. ម្យាងវិញទៀត មូលនិធិអក្ខរកម្មពិភពលោក នៃសាកលវិទ្យាល័យ Oxford ចក្រភពអង់គ្លេស បានសម្រេចជ្រើសរើសស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺក្រសួងអប់រំ ដើម្បីទទួលពានរង្វាន់អក្ខរកម្មពិភពលោក ដែលបានធ្វើឱ្យវិស័យអប់រំនៅកម្ពុជាមានភាពប្រសើរឡើងក្នុងរយៈពេលកន្លងមក ហើយពានរង្វាន់នេះនឹងទទួលនៅ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ នៅសាកលវិទ្យាល័យ Oxford ចក្រភពអង់គ្លេស ដោយសាររាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយគាំទ្រដល់វិស័យអប់រំ ពិសេសការរីកចម្រើនក្នុងវិស័យអប់រំ ពោលគឺកុមារកម្ពុជា ចេះអាន ចេះគិតលេខទាំងអស់គ្នា។

.ក្នុងបរិបទជំងឺកូវីដ-១៩ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រ ការអប់រំតាមបែបឌីជីថលក្នុងគោលដៅដើម្បីធានាបន្តនិរន្តរភាពដល់ការបង្រៀន និងរៀនរបស់គ្រូ និងសិស្ស ដោយបង្រៀនពីចម្ងាយ និងការបង្រៀនតាមបណ្តុំនិងការផលិតវីដេអូបង្រៀន ការបែងចែកសន្លឹកកិច្ចការឱ្យសិស្សធ្វើនៅផ្ទះ និងការបង្ហោះមេរៀនផ្សព្វផ្សាយតាមបណ្តាញផ្សព្វផ្សាយផ្លូវការរបស់ក្រសួងព្រមទាំងការសហការជាមួយក្រសួងព័ត៌មានបង្កើតទូរទស្សន៍តេជោ ដើម្បីពង្រីកការបង្រៀន និងរៀននៅតាមទីជនបទ ។

.ការថ្លែងអំណរគុណជូនសម្តេចតេជោ នាយករដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ មាតាបិតា និងសប្បុរសជន ដែលបានចូលរួមគាំទ្រការអប់រំតាមបែបឌីជីថល ក្នុងការទទួលបានផ្លែផ្កាដូចពេលនេះ

. ការប្រារព្ធទិវាជាតិអំណានក្នុងជំណាក់កាលកូវីដ-១៩ ក្រសួងបានរៀបចំតាមអនឡាញនិងកូនកាត់ (ពាក់កណ្តាលអនឡាញ)មានការប្រកួតប្រជែងគ្រប់ផ្នែក ការប្រារព្ធពិធីទិវាជាតិ និងសប្តាហ៍សៀវភៅ។ ក្រៅពីនេះក្រសួង បានផ្សព្វផ្សាយតាមអនឡាញ មានផ្ទាំងរូបភាព និងវីដេអូឃ្លីប អំពីសៀវភៅល្អៗ សៀវភៅចេញថ្មី និងការដាក់តាំងលក់បញ្ចុះថ្លៃសៀវភៅ។ ក្រសួងបានរៀបចំវេទិកា ពិភាក្សាតាមអនឡាញនិងមាន វីដេអូ ឃ្លីបមួយចំនួន ដែលបង្ហាញអំពី ទម្លាប់និងសារៈសំខាន់នៃការអាន របស់សិស្សឆ្នើម ដែលបច្ចុប្បន្នបានទទួលអាហារូបករណ៍ទៅសិក្សានៅក្នុងនិងក្រៅប្រទេស

.ប្រធានបទនៃទិវាជាតិអំណាន ១១ មីនា ២០២៣ " *អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ* " មានគោលដៅឆ្លុះបញ្ចាំងពីអំណានជាមាគ៌ាជំរុញឱ្យមានការប្រែប្រួលធ្វើឱ្យមានការផ្លាស់ប្តូរទស្សនវិស័យ ការគិត និងការប្រតិបត្តិនៃបរិស្ថានជុំវិញដើម្បីឆ្លើយតបនឹងការវិវឌ្ឍនៃសង្គមសេដ្ឋកិច្ចរួមទាំងវិស័យអប់រំ។

.ក្នុងខណៈដែលអំណានមានការវិវឌ្ឍទាំងផ្នែកឥរិយាបថ និងតម្រូវការផ្គត់ផ្គង់ វិស័យអប់រំត្រូវតែមានភាពឆ្លើយតបនឹងឌីជីថលូបនីយកម្ម ៖ ១ .ការប្រែប្រួលគោលនយោបាយ និងចក្ខុវិស័យ ២.ការប្រែប្រួលការបង្រៀន និងរៀន ប្រែក្លាយពីការបង្រៀនតាមបែបប្រពៃណីមកតាមបែបឌីជីថល ៣.កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល នៅតាមអង្គភាពអប់រំ និងតាមសាលារៀន

. សម្រាប់ឆ្នាំនេះ ការរៀបចំទិវាជាតិអំណាន ក្រសួងបានរៀបចំឱ្យមានការប្រកួតប្រជែងអាន សូត្រកំណាព្យតែងនិពន្ធ និងការប្រកួតប្រជែងបកស្រាយប្រធានបទ ស្តីពី " **គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល** " កិច្ចពិភាក្សាពី " **សារៈសំខាន់របស់អំណានក្នុងការសិក្សា** " និងការធ្វើបាឋកថាស្តីពី " **វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងបរិបទនៃការអប់រំក្នុងសតវត្សទី២១** " ដោយរូបលោកផ្ទាល់ ។

## ខ. សុន្ទរកថាបើកការប្រោព្ធពិធីទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣



សម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចមានប្រសាសន៍បើកការប្រោព្ធទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣ មានខ្លឹមសារដូចខាងក្រោម៖

. ការសំដែងក្ដីសោមនស្សរីករាយ ចំពោះការចូលរួមក្នុងពិធីប្រារព្ធទិវាជាតិអំណាន ១១មីនា ២០២៣ ក្រោមប្រធានបទ "*អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ*" នាពេលនេះ

. សម្ដេចសូមគាំទ្រប្រធានបទឆ្នាំ២០២៣នេះ ដែលបានឆ្លុះបញ្ចាំងឱ្យឃើញពីសារៈសំខាន់របស់អំណាននៅក្នុងការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយសមត្ថភាព និងគុណសម្បត្តិ គ្រប់ផ្នែក ព្រមទាំងមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា កាយសម្បទា និងមនសិកាស្នេហាជាតិ

. ម្យ៉ាងទៀតលោកជំទាវយល់ថាប្រធានបទទិវាជាតិអំណានឆ្នាំ២០២៣នេះ ពិតជាត្រឹមត្រូវស្របតាមកាលទេសៈបច្ចុប្បន្ន និងចំពេលដែលសង្គមជាតិយើង និងពិភពលោកទាំងមូល កំពុងមានការប្រែប្រួលយ៉ាងឆាប់រហ័សក្នុងវិស័យអប់រំ

. ការអប់រំ ការរៀនសូត្រ និងការបង្រៀន ផ្ដោតលើការអានអក្សរ ការគណនាលេខនិពន្ធ ការពិសោធន៍ និងការសិក្សាស្រាវជ្រាវ ដែលបានធ្វើឡើងនៅថ្នាក់រៀនពិតជាមិនគ្រប់គ្រាន់ទេ តែការអប់រំបានវិវឌ្ឍចូលជ្រៅទៅក្នុងបច្ចេកវិទ្យា ឌីជីថល។ជាក់ស្ដែងកាលពីជំណាក់កាលជំងឺកូវីដ១៩ ដែលបានរាលដាលខ្លាំង ក្រសួងអប់រំ យុវជន និងកីឡា បានប្រែក្លាយវិបត្តិកូវីដ១៩ ទៅជាឱកាសធ្វើកំណែទម្រង់វិស័យអប់រំ ដោយធ្វើសមាហរណកម្មបច្ចេកវិទ្យាឌីជីថល ឬ ការអប់រំតាមបែបឌីជីថល ដោយមានកម្មវិធីបង្រៀនតាមអនឡាញ

. ការកោតសរសើរនិងវាយតម្លៃខ្ពស់គំនិតផ្ដួចផ្ដើម និងកិច្ចខិតខំប្រឹងប្រែង និងការចូលរួមអនុវត្តដោយខិតខំទប់ទល់នឹងជំងឺកូវីដ១៩ផង និងការជានានិរន្តរភាព នៃការបង្រៀន និងរៀនផង និងការទទួលបានការអប់រំ តាមគ្រប់រូបភាពផង

. ក្រៅពីអំណានតាមសៀវភៅ និងឯកសារបោះពុម្ពផ្សេងទៀតប្រជាជនយើងភាគច្រើនបាននិយមប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ជាជំនួយដ៏មានប្រយោជន៍ និងមានប្រសិទ្ធភាព និងមានភាពទាក់ទាញសម្រាប់ការអានជាទូទៅ តាមរយៈទូរស័ព្ទវៃឆ្លាត ថេបផ្លេត និងកុំព្យូទ័រជាដើម ដែលសុទ្ធសឹងជាឧបករណ៍អានដ៏ពេញនិយមសម្រាប់អ្នកសិក្សា និងប្រជាពលរដ្ឋទូទៅក្នុងសម័យថ្មី នៃបច្ចេកវិទ្យាឌីជីថល

. អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើបបែបនេះធ្វើឱ្យអ្នកអាន បានចំណេញពេលវេលា ងាយស្រួល រក្សាទុក និងងាយស្រួលស្វែងរកព័ត៌មាន ព្រមទាំងជួយដល់ការការពារបរិស្ថានផងដែរ

. ដោយឡែក សិស្សានុសិស្ស និស្សិត និងយុវជនកម្ពុជាភាគច្រើន ក៏កំពុងតែពេញនិយមក្នុងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ដែលជាមធ្យោបាយដ៏សំខាន់សម្រាប់អំណានប្រចាំថ្ងៃផងដែរ។

. សម្ដេច បានលើកគម្រូការអានដ៏ល្អ១៩៨០-១៩៨១ ក្នុងយុគសម័យការកសាងផង និងការការពារផង ពិសេសការការពារពីការវិលមកវិញនៅរបបប៉ុលពតផង និងអភិវឌ្ឍសង្គមពិសេសការសិក្សាសម្រាប់អភិវឌ្ឍវិស័យអប់រំ ដោយបំផុសឱ្យក្មេងចូលរៀន

. ការអាន អាចជាគម្រូល្អមួយសម្រាប់ក្មួយៗជំនាន់ក្រោយ ការចាប់សៀវភៅអានក៏ជាទង្វើល្អមួយដែលឪពុកម្តាយមិនគួរមើលរំលង

. ការដាក់សៀវភៅនៅតាមខ្លួនសម្រាប់អានជាប្រចាំជាការល្អ និងជាឥទ្ធិពល វិជ្ជមានជុំវិញដើម្បីបណ្តុះទឹកចិត្តអ្នកជុំវិញឱ្យស្រឡាញ់ការអានផងដែរ

. សម្តេច មានប្រសាសន៍ថា យើងជួបការលំបាកច្រើនណាស់ ទំរាំមានសុខសន្តិភាព និងការអភិវឌ្ឍន៍ និងការរីកចម្រើនមកទល់ពេលនេះ ពិតជាមានការលំបាកណាស់ គឺវាអាស្រ័យដោយមានការដឹកនាំ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ខិតខំរំដោះប្រទេសរកគ្រប់វិធី នយោបាយឈ្នះៗ

. ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រី យើងមានសុខសន្តិភាព និងមានការអភិវឌ្ឍលើគ្រប់វិស័យ ក្នុងនោះក៏មានវិស័យអប់រំផងដែរ ដែលជាវិស័យអាទិភាពត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ និងបានធ្វើកំណែទម្រង់ស៊ីជម្រៅជាបន្តបន្ទាប់ និងបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ និងផែនការទី៤ យុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដើម្បីជម្រុញឱ្យការបណ្តុះបណ្តាលធនធានមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព និងឈានទៅរកការប្រកួតប្រជែងទាំងក្នុងប្រទេស ទាំងក្នុងតំបន់។

**ជោគជ័យថ្មីៗរបស់រាជរដ្ឋាភិបាល**

១. កម្ពុជាបានក្លាយជាប្រទេសដែលគ្រប់គ្រងទប់ទល់និងបានងើបចេញពីជំងឺកូវីដ១៩បានយ៉ាងល្អប្រសើរ ដែលបានបើកដំណើរការប្រទេសឡើងវិញ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១

២. ការទទួលបានកិច្ចប្រជុំអាស៊ាន អន្តរអាស៊ានIPA និងកិច្ចប្រជុំពាក់ព័ន្ធជាច្រើនទៀតនៅកម្ពុជា ដែលធ្វើឱ្យពិភពលោកកោតស្ញប់ស្ញែងក្នុងនាមជាប្រធានអាស៊ានប្តូរវេន និងម្ចាស់ផ្ទះប្រធានអាស៊ាន កាលពីចុងឆ្នាំ ២០២២

៣. ជោគជ័យកិច្ចប្រជុំរដ្ឋមន្ត្រីអប់រំអាស៊ានបូក៦ លើកទី៦ នៅទីក្រុងហាណូយថ្ងៃទី១៤ខែតុលាឆ្នាំ២០២២ ក្រោមមូលបទ " *កិច្ចប្រឹងប្រែងរួមគ្នាដើម្បីស្តារការសិក្សាឡើងវិញ និងការកសាងភាពធន់ប្រព័ន្ធអប់រំនៅក្នុងតំបន់ និងក្រៅតំបន់អាស៊ាននៅក្នុងបរិបទថ្មី* " ចំណុចនេះបានបង្ហាញយ៉ាងច្បាស់ពីការចូលរួមចំណែករបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រឹង និងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

. ដោយឡែកឆ្នាំ២០២៣ យើងមានព្រឹត្តិការណ៍ជាតិសំខាន់ចំនួន២ គឺ

១. ជាម្ចាស់ផ្ទះកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ និងថ្ងៃទី២១ ខែមីនា ឆ្នាំ ២០២៣ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ព្រះអង្គសព្វព្រះរាជហឫទ័យ នឹងស្តេចយាងជាធិបតីក្នុងព្រះរាជពិធីសុំភ្លើង ព្រះអាទិទេពកីឡា នៅប្រាសាទអង្គរវត្ត

២. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលនឹងប្រព្រឹត្តទៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២៣

. បើទោះបីយើងមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចសង្គម និងបច្ចេកវិទ្យា ក៏ទាមទារឱ្យយើងខិតខំបន្តកែលម្អ និងពង្រឹងគុណភាពអប់រំបន្ថែមទៀត សំដៅឈានទៅសម្រេចឱ្យបានជោគជ័យ យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល

. កម្ពុជា ពិតជាត្រូវការធនធានមនុស្សដែលមានសមត្ថភាព ដើម្បីចូលបម្រើការងារទាំងផ្នែករដ្ឋ និងឯកជន ជាពិសេសទាំងក្នុងក្រុមហ៊ុន វិនិយោគទន់បរទេសដែលត្រូវការបុគ្គលិកជំនាញ

. ដូច្នេះ អំណាន ពិតជារួមចំណែកពង្រឹងសមត្ថភាពចំណេះដឹងទូទៅ ជំនាញឯកទេស និងភាសាបរទេស ដែលជាមធ្យោបាយផ្លាស់ប្ដូរព័ត៌មាន និងបទពិសោធន៍ឱ្យបានទូលំទូលាយទាំងក្នុង និងក្រៅប្រទេស

. ក្នុងបរិការដែលបញ្ហានយោបាយសេដ្ឋកិច្ច និងបច្ចេកវិទ្យាលើពិភពលោកមានភាពស្មុគស្មាញ ពិបាកវាយតម្លៃ និងព្យាករណ៍នាពេលបច្ចុប្បន្ននេះ កម្ពុជាត្រូវការធនធានមនុស្សដែលមានសមត្ថភាព ដើម្បីចូលរួមកសាងប្រទេសជាតិ បង្កើនភាពប្រកួតប្រជែងលើគ្រប់វិស័យ និងធ្វើពិពិធកម្មសេដ្ឋកិច្ច

.ការអភិវឌ្ឍធនធានមនុស្សមិនអាចធ្វើទៅបានទេ បើខ្វះការបង្កើនសមត្ថភាព ការស្រាវជ្រាវ និងអំណាន

. ប្រការនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវមានឆន្ទះមុតស្រួច និងទស្សនវិស័យ វែងឆ្ងាយក្នុងការបន្តជម្រុញនិងលើកកម្ពស់តួនាទីអំណានព្រមទាំងពង្រីកវិសាលភាពឱ្យកាន់តែទូលំទូលាយនៅទូទាំងប្រទេស

. សម្ដេចបានអំពាវនាវដល់អ្នកពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងសប្បុរសជនទាំងអស់ បន្តចូលរួម និងសហការ និងគាំទ្រទិវាជាតិអំណាន ១១ មីនា ដោយបង្កើតឱ្យមានកម្មវិធីកាន់តែសម្បូរបែបប្រកបដោយគុណភាព និងប្រសិទ្ធភាពជាបន្តទៀត ដោយជំរុញស្មារតីប្រជាជនកម្ពុជាឱ្យបង្កើនការចាប់អារម្មណ៍ចំពោះការអាន បង្កើត ទម្លាប់អាន និងបង្កើនការតែងនិពន្ធឱ្យកាន់តែសកម្ម និងរស់រវើក

. សម្ដេចក៏បានអំពាវនាវផងដែរ ដល់ប្រជាពលរដ្ឋយើងទាំងអស់ ពិសេសយុវជននិង សិស្សានុសិស្ស សូមបង្កើនការអានឱ្យបានច្រើន ព្រោះអំណានមានសារៈសំខាន់ជាច្រើន ដូចជា បំណិនខាងទំនាក់ទំនង ធ្វើឱ្យខួរក្បាលមានសុខភាពល្អ ផ្ដល់ការអប់រំ កាត់បន្ថយភាពតប់ប្រមល់ ឬស្ត្រេស និងកង្វល់ បង្កើនភាពជឿជាក់ និងច្នៃប្រឌិត និងបង្កើនលទ្ធភាពសរសេរ ។ល។

. សម្ដេចបានកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងយកអស់កម្លាំងចិត្ត និងធនធានសព្វគ្រប់ ដើម្បីបណ្ដុះទម្លាប់អាន ជម្រុញវប្បធម៌អាន លើកកម្ពស់ សមត្ថភាពអាន ការតែងនិពន្ធនិងការស្រាវជ្រាវរបស់លោកគ្រូអ្នកគ្រូ អ្នកស្រាវជ្រាវ និងក្មួយៗ សិស្សានុសិស្ស និស្សិត យុវជន របស់យើង យ៉ាងក្លៀវក្លាសកម្មនាពេលកន្លងមក និងទៅអនាគត ។

. ក្រសួងអប់រំ និងមន្ទីរអប់រំត្រូវត្រៀមនូវសម្ភារៈសម្រាប់លើកទឹកចិត្ត និងការគាំទ្រដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ដែលបានខិតខំនិពន្ធតាក់តែងនូវខ្លឹមសារ ចលនាអប់រំ ដើម្បីឱ្យយើងទាំងអស់គ្នា ចូលចិត្តអាន ចូលចិត្តទិវាជាតិអំណាននេះផងដែរ ។

. សម្ដេចបានវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងការរៀបចំពិធីដ៏មានសារៈសំខាន់ ដោយកំណត់យកថ្ងៃ ១១ មីនា ជាថ្ងៃកំណើតរបស់ព្រះសង្ឃរាជ ជួន ណាត ដើម្បីរំលឹកដល់គុណូបការៈរបស់ព្រះអង្គដែលបានខិតខំថែរក្សាវប្បធម៌ជាតិ និងអក្សរសាស្ត្រជាតិ ។

*សូមឱ្យស្មារតីទិវាជាតិអំណាន ១១ មីនា ស្ថិតក្នុងស្មារតីប្រជាពលរដ្ឋគ្រប់រូប*

### *គ. ពិធីប្រគល់ពានរង្វាន់ជ័យលាភី*

សម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី បានជូន " **ពានរង្វាន់សម្ដេចតេជោ ហ៊ុន សែន** " ប្រាក់រង្វាន់លើកទឹក និងប្រកាសនីយបត្រ សម្រាប់បេក្ខជនជ័យលាភីផ្នែកអានអត្ថបទ ស្ងូតកំណាព្យ និងតែងនិពន្ធ និងជូនប្រាក់រង្វាន់លើកទឹក និងប្រកាសនីយបត្រ សម្រាប់បេក្ខជនជ័យលាភីផ្នែក បកស្រាយប្រធានបទ មានដូចខាងក្រោម ៖

**ជ័យលាភីផ្នែក អានអត្ថបទ**

**ជ័យលាភីលេខ១**



កុមារី **លេខា សៀវម៉ី**
សាលាបឋមសិក្សាបរន.ហស.អនុវត្ត
ខេត្តកណ្ដាល

**ជ័យលាភីលេខ២**



កុមារី **សៅ ឆេងហួយ**
សាលាបឋមសិក្សាក្អិន
ខេត្តកំពង់ធំ

**ជ័យលាភីលេខ៣**



កុមារី **ស៊ឹម ស្រីលក្ខណ៍**
សាលាបឋមសិក្សាណាមីកូភ្នំសសៀរ
ខេត្តកែប

**ជ័យលាភីផ្នែក ស្មូតកំណាព្យ**

**ជ័យលាភីលេខ១**



កុមារី **សាត់ ស្រីណុច**
វិទ្យាល័យសម្ដេចឪ សម្ដេចម៉ែ បរសេដ្ឋ
ខេត្តកំពង់ស្ពឺ

**ជ័យលាភីលេខ២**



កុមារា **នៅ កោសល្យ**
វិទ្យាល័យហ៊ុនសែនបុរី១០០ខ្នង
រាជធានីភ្នំពេញ

**ជ័យលាភីលេខ៣**



កុមារា **សំរេច រួន**
អនុវិទ្យាល័យពោធិ៍វង្ស
ខេត្តឧត្តរមានជ័យ

**ជ័យលាភីផ្នែក តែងនិពន្ធ**

**ជ័យលាភីលេខ១**



យុវតី **ឃឹម សូនីតា**
វិទ្យាល័យសម្ដេចតេជោហស.រលាំងឈូក
ខេត្តកំពង់ស្ពឺ

**ជ័យលាភីលេខ២**



យុវតី **អ៊ឹម អែម**
វិទ្យាល័យកំពង់ធំ
ខេត្តកំពង់ធំ

**ជ័យលាភីលេខ៣**



យុវជន **សុភាជ វិសិដ្ឋ**
វិទ្យាល័យ មេសាង
ខេត្តព្រៃវែង

**ជ័យលាភីផ្នែក បកស្រាយប្រធានបទ**

| **ជ័យលាភីលេខ១** | **ជ័យលាភីលេខ២** | **ជ័យលាភីលេខ៣** |
|---|---|---|
|  |  |  |
| លោក **មុី សុវណ្ណ** គ្រូបង្រៀន វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | លោក **មិន ម៉ៅសំណាង** អ្នកសារព័ត៌មាន ស្ថានីយ៍ទូរទស្សន៍ ភី.អិន.អិន | លោក **ទឹម សុខហួយ** គ្រូបង្រៀន វិ.សអគហស.តាកែវ |

**បញ្ជាក់៖ ក.** គ្រប់បេក្ខជនជ័យលាភីទាំង៣ វិញ្ញាសា និងទាំង៣កម្រិត៖

. ចំពោះបេក្ខជនជ័យលាភី ក្រៅពីប្រាន់រង្វាន់លើកទឹកចិត្តនេះ បេក្ខជនទាំងអស់នឹងទទួលបានក្នុងម្នាក់ៗ បន្ថែមទៀតគឺ " **ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន** "១ , ប្រកាសនីយបត្រ១, Kindle White Paper ១ និងកាបូប១ ។

. បេក្ខជនមិនបានទទួលជ័យលាភី៦៦ នាក់ ក៏ទទួលលិខិតថ្លែងអំណរគុណ ១ និងកាបូប១ ផងដែរ។

**ខ.**បេក្ខជនជ័យលាភីបកស្រាយប្រធានបទក្រៅពីប្រាក់រង្វាន់លើកទឹកចិត្តក៏ទទួលបានប្រកាសនីយបត្រ១

***ឃ.ការអានអត្ថបទរបស់បេក្ខជនជ័យលាភីលេខ១ ផ្នែកអានអត្ថបទ***



កុមារី **លេខា សៀវម៉ី** ជ័យលាភីលេខ១ និងជាសិស្សមកពី សាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន អនុវត្ត ខេត្តកណ្តាល បានអាន អត្ថបទ មានចំណងជើងថា " **អំណានជាមាគ៌ាឆ្ពោះទៅរកភាពជោគជ័យ** " ។

***ង.ការសូត្រកំណាព្យរបស់បេក្ខជនជ័យលាភីលេខ១ ផ្នែកសូត្រកំណាព្យ***



កុមារី **សាត់ ស្រីណុច** ជ័យលាភីលេខ១ និងជាសិស្សមកពីវិទ្យាល័យសម្តេចឪ សម្តេចម៉ែ បរសេដ្ឋខេត្តកំពង់ស្ពឺ បានសូត្រកំណាព្យមួយបទ មានចំណងជើងថា " **អំណានជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត** " ជាស្នាដៃនិពន្ធរបស់កុមារី **ឃឹម សូនីតា** ជាបេក្ខជនជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ និងជាសិស្សមកពី វិទ្យាល័យសម្តេចតេជោ ហ៊ុន សែន រលាំងឈូក ខេត្តកំពង់ស្ពឺ។

***ច.បាឋកថាស្រាវជ្រាវ ស្តីពី " វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ក្នុងបរិបទនៃការអប់រំក្នុងសតវត្សទី២១ "***



រៀងរាល់ឆ្នាំការរៀបចំប្រារព្ធពិធីទិវាជាតិអំណាន ក្រៅពីកម្មវិធីផ្សេងៗក្នុងទិវាជាតិ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** លោកតែងបានរៀបចំនូវបាឋកថា ដែលមានខ្លឹមសារឆ្លើយតបប្រធានបទទិវាជាតិអំណាន។ ជាក់ស្តែងក្នុងទិវាជាតិអំណាន លើកទី៨ ១១មីនា ឆ្នាំ២០២៣នេះ **ឯកឧត្តមបណ្ឌិតសភាចារ្យ**

បានរៀបចំបាឋកថាស្រាវជ្រាវស្តីពី "*វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ក្នុងបរិបទនៃការអប់រំក្នុងសតវត្សទី២១*" ដែលជាស្នាដៃនិពន្ធទី៣៦ មកធ្វើបទបង្ហាញជូនដល់អង្គពិធី និងសាធារណៈជន ពិសេសលោកគ្រូ អ្នកគ្រូ សិស្ស និស្សិត បានយល់ដឹងពីរបៀបវាយតម្លៃលទ្ធផលសិក្សាក្នុងបរិបទអប់រំសតវត្សទី២១នេះ។ ខ្លឹមសារសំខាន់ៗ មានៈ

**ជំពូក១ ក្របខណ្ឌវាយតម្លៃ**

១.១ និយមន័យវាយតម្លៃលទ្ធផលសិក្សា, វាយតម្លៃការសិក្សារបស់សិស្សតាមដំណាក់កាល, វាយតម្លៃសិក្សាតាមបែបសរុប និងភាពខុសគ្នា

១.២ វាយតម្លៃសិក្សាក្នុងកំណែទម្រង់វិស័យអប់រំ និង១.៣ ភាពជាអ្នកដឹកនាំវាយតម្លៃ

**ជំពូក២ ក្របខណ្ឌវាយតម្លៃសិក្សា**

២.១ ក្របខណ្ឌវាយតម្លៃលទ្ធផលសិក្សាសិស្ស, ការវាយតម្លៃផ្ទៃក្រៅ និងការវាយតម្លៃផ្ទៃក្នុង

២.២ ការវាយតម្លៃថ្នាក់ជាតិ ( ថ្នាក់ទី៣,៦,៨ និងទី១១ )

២.៣ កម្មវិធីអន្តរជាតិ ស្តីពីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ( PISA-D )

២.៤ វាយតម្លៃថ្នាក់តំបន់ SEA-PLM

**ជំពូក៣ អធិការកិច្ចសាលារៀនតាមកាលកំណត់**

៣.១ ប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ, ៣.២ អធិការកិច្ចសាលារៀនតាមកាលកំណត់

៣.៣ ទំនាក់ទំនងរបស់អ្នកទទួលបន្ទុក ក្នុងការពិនិត្យតាមដានសាលារៀនថ្នាក់ក្រុង ស្រុក ខណ្ឌ

**ជំពូក ៤ វាយតម្លៃសិក្សា និងកំណែទម្រង់ការគ្រប់គ្រងសាលារៀន**

៤.១ ការគ្រប់គ្រងតាមសាលារៀន ៤.២ អធិការកិច្ចសាលារៀន ៤.៣ ការគ្រប់គ្រងសាលារៀន(SBM)

៤.៤ គោលការណ៍សំខាន់ៗសម្រាប់អនុវត្តការគ្រប់គ្រងសាលារៀន ៤.៥ យុទ្ធសាស្ត្រ ៦A

៤.៦ អនុវត្តយុទ្ធសាស្ត្រនាំឱ្យមានការផ្លាស់ប្តូរ ៤.៧ រៀបចំផែនការកែលម្អសាលារៀន

៤.៨ បង្កើតវប្បធម៌ជួយសិស្សតាមរយៈតេស្ត

៤.៩ សកម្មភាពសព្វគ្រប់នៃការធ្វើតេស្តស្តង់ដារវាយតម្លៃសមត្ថភាពសិស្ស

៤.១០ ផែនការបង្រៀនដោយប្រើលទ្ធផលពីការធ្វើតេស្តស្តង់ដា

៤.១១ ការលើកទឹកចិត្តសិស្សរៀនយឺត និងការប្រជុំជាមួយមាតាបិតាប្រចាំខែ

**ជំពូក៥ ការសិក្សា និងវាយតម្លៃក្នុងសតវត្សទី២១**

៥.១ កំណែទម្រង់វាយតម្លៃសិក្សារបស់សិស្ស

៥.២ ការកែលម្អវិធីសាស្ត្របង្រៀន នៅសាលារៀនជំនាន់ថ្មី (NGS)

៥.៣ វិធីសាស្ត្រវាយតម្លៃសិក្សានៅសាលារៀនជំនាន់ថ្មី (NGS )

៥.៤ ការវាយតម្លៃក្នុងការសិក្សាអក្សរសិល្ប៍,៥.៥ ការវាយតម្លៃក្នុងការរិះរក ក្នុងការរៀនវិទ្យាសាស្ត្រ។

## *៩.២ កម្មវិធីពេលរសៀល*

ការប្រារព្ធទិវាជាតិអំណានលើកទី៨ នារសៀលថ្ងៃសៅរ៍ ទី១១ ខែមីនា ឆ្នាំ២០២៣ បានស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង លោក លោកស្រី ជាថ្នាក់ដឹកនាំនិងមន្ត្រីជំនាញមកពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ទាំងគ្រឹះស្ថាន

សិក្សាសាធារណៈ និងឯកជន សរុប ៣១៣៩ នាក់។

*ក. ការទស្សនាខ្សែវីដេអូ ស្តីពី "បណ្ណាល័យយើង ដើម្បីកូនចៅយើង"*

វីដេអូនេះ ជាការរៀបចំរបស់អង្គការ រូមធូរីដ ដែលមានខ្លឹមសារបង្ហាញពីការអភិវឌ្ឍបណ្ណាល័យតាមរយៈការចូលរួមរបស់អ្នកពាក់ព័ន្ធផ្សេងៗ ជាពិសេសសហគមន៍ និងចំណង់ចំណូលចិត្តរបស់សិស្សក្នុងការអានសៀវភៅ

*ខ.ការសូត្រកំណាព្យរបស់បេក្ខជនជ័យលាភីលេខ២ ផ្នែកសូត្រកំណាព្យ*



កុមារ **នៅ កោសល្យ** ជាជ័យលាភីលេខ២ និងជាសិស្សរៀនវិទ្យាល័យ ហ៊ុន សែន បុរី១០០ខ្នង រាជធានីភ្នំពេញ បានសូត្រកំណាព្យមួយបទ មានចំណងជើងថា "អំណានជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត" ជាស្នាដៃនិពន្ធរបស់កុមារី **អ៊ឹម អែម** ជាបេក្ខជនជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ សិស្សរៀនវិទ្យាល័យកំពង់ធំ (ស្ទឹងសែន)ខេត្តកំពង់ធំ។

*គ. វេទិកាពិភាក្សា ស្តីពី "សារៈសំខាន់របស់អំណានក្នុងការសិក្សា"*



វេទិកាពិភាក្សានេះ ត្រូវបានសម្របសម្រួលដោយលោកជំទាវបណ្ឌិត **ឃួន ទិច្ឆិកា** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមជាវាគ្មិនក្នុងឱកាសនោះមាន ៖

១. ព្រះមុនីកោសល្យបណ្ឌិត **យ៉ន សេងយៀត** សាកលវិទ្យាធិការរងនៃពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ
២. លោកសាស្ត្រាចារ្យបណ្ឌិត **អាំង ជូលាន** ជានរវិទូខ្មែរ១រូប បានទទួលរង្វាន់ធ្មេម ហ្វ៊ូគូអូកា នៃប្រទេសជប៉ុន

ជាកិច្ចចាប់ផ្តើម លោកជំទាវបណ្ឌិត **ឃួន ទិច្ឆិកា** បានអរគុណ និងអរព្រះគុណដល់ព្រះតេជគុណ និងលោកបណ្ឌិត ដែលបាននិមន្តអញ្ជើញចូលរួមជាវាគ្មិននៃវេទិកាកិច្ចពិភាក្សា ស្តីពី "*សារៈសំខាន់របស់អំណានក្នុងការសិក្សា*" ដើម្បីចែករំលែកបទពិសោធន៍កន្លងមកថា តើអំណានជាមាគ៌ាឆ្ពោះទៅ កសាងបរិវត្តកម្មនៃវិស័យអប់រំបែបណា ដោយសារតែយើងបានឃើញហើយថា ព្រះតេជគុណ និងលោកសាស្ត្រាចារ្យ បណ្ឌិត មានបទពិសោធន៍បានឆ្លងកាត់ ការអាន ការស្រាវជ្រាវ និងការនិពន្ធរហូតមានការទទួលស្គាល់ ជាកម្រិតអន្តរជាតិ ។

ប្រវត្តិសង្ខេបរបស់ ព្រះមុនីកោសល្យ **យ៉ន សេងយៀត** និងលោកសាស្ត្រាចារ្យបណ្ឌិត **អាំង ជូលាន**



. ព្រះមុនីកោសល្យ **យ៉ន សេងយៀត** សកលវិទ្យាធិការរងទទួលបន្ទុកដឹកនាំពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ ព្រះអង្គបានបញ្ចប់ការសិក្សានៅសកលវិទ្យាល័យ HARWORD កម្រិតក្រោយបណ្ឌិត និងបានបួសរៀនអស់រយៈពេល៣១ ឆ្នាំ ហើយក្រៅពីការខិតខំសិក្សាស្រាវជ្រាវ និងរៀនសូត្រព្រះអង្គក៏មានបទពិសោធន៍ជាច្រើនទៀតក្នុងការងារ

បច្ចុប្បន្ន ព្រះអង្គកំពុងតែចូលរួមយ៉ាងសកម្មក្នុងការលើកស្ទួយការអប់រំក្នុងព្រះពុទ្ធសាសនាហើយបទពិសោធន៍របស់ព្រះអង្គក៏ធ្លាប់ឆ្លងកាត់ការចូលរួមការចែករំលែក ក្នុងសន្និសីទអន្តរជាតិអស់ជាង៥០ ប្រទេសមកហើយដែរ។

. លោកសាស្ត្រាចារ្យបណ្ឌិត **អាំង ជូលាន** ជានរវិទូខ្មែរដ៏ឆ្នើមមួយរូប ដែលស្រាវជ្រាវទាក់ទងនឹងនរវិទ្យា



បុរាណវិទ្យា ប្រពៃណី ទំនៀមទំលាប់ខ្មែរ។ ក្រៅពីការខិតខំសិក្សាស្រាវជ្រាវនេះលោកបណ្ឌិត បានចូលរួមការងារជាច្រើនពិសេសការងារនិពន្ធ ស្រាវជ្រាវ និងបង្រៀននៅសាកលវិទ្យាល័យ ដើម្បីបានចែករំលែកចំណេះដឹង និងរបកគំហើញនានាទៅកាន់គរុនិស្សិតផងដែរ។ នៅឆ្នាំ២០១១ លោកសាស្ត្រាចារ្យបណ្ឌិត ទទួលបាននូវរង្វាន់ឆ្នើមហ្វូកូអ៊ូកានៃប្រទេសជប៉ុនដែលជាពានរង្វាន់មួយរៀបចំដោយទីក្រុងហ្វូកូអ៊ូកានៅប្រទេសជប៉ុនក្នុងទិសដៅទទួលស្គាល់ និងផ្តល់កិត្តិយសចំពោះបុគ្គលមានស្នាដៃឆ្នើម ស្ថាប័នឆ្នើម ដែលបានអភិរក្ស និងផ្ទៃប្រឌិតខ្ពស់ទាក់ទងទៅនឹងវប្បធម៌អាស៊ី។

*លទ្ធផលខ្លឹមសារនៃសំណួរចម្លើយ ក្នុងកិច្ចពិភាក្សា*

**សំណួរ** តើមានកត្តាអ្វីខ្លះ បានជាព្រះអង្គសម្រេចចិត្តបួសរៀនតាំងពីកុមារភាព?

តើមានកត្តាអ្វីខ្លះបានធ្វើឱ្យព្រះអង្គមានភាពជោគជ័យក្នុងការសិក្សា និងស្រាវជ្រាវរហូតមកដល់ពេលនេះ ?

**សង្ឃដីការព្រះអង្គ**

. បួសតាំងពីឆ្នាំ១៩៩១ មិនមែនបួសដោយចង់បួសទេ កាលនោះជីតាស្លាប់អាចារ្យប្រាប់ថា តាមប្រពៃណីខ្មែរគេឱ្យបួសមុខភ្លើង និងបានប្រាប់ក្រុមគ្រួសារលោកថា ឱ្យមានកូនប្រុសណាម្នាក់បួស៣ម៉ោងទៅ ល្មមបូជាសពសុះសឹកមកវិញបានហើយ។ពេលនោះព្រះអង្គក៏ត្រូវបានបំបួស តែមកទល់ពេលនេះគឺ៣០ឆ្នាំ។

. បន្ទាប់ពីបួសរួច ជីដូនបានយកលោកទៅផ្ញើលោកគ្រូចៅអធិការវត្តមួយអង្គដែលលោកគ្រូចេះអន្ទងព្រលឹងក្មេងឱ្យស្រឡាញ់ ចេះរស់នៅក្នុងវត្ត លោកចេះនិយាយពិរោះល្មមស្តាប់បានដែលធ្វើឱ្យព្រះតេជគុណយល់ថាវត្តគឺល្អជាងផ្ទះ។ លោកគ្រូចៅអធិការវត្ត លោកចេះនិយាយ ឱ្យអានរឿងគ្រប់សព្វបែបយ៉ាងឱ្យលោកស្តាប់ ពេលលោកសឹងនិងធាន់រួច និងឆ្លងកាត់មកក៏បានទៅរៀននៅប្រទេសស្រីលង្កាបានជិត១០ឆ្នាំ និងត្រឡប់មកស្រុកខ្មែរវិញសិក្សារហូតឆ្នាំ២០១៦ ក៏បានទទួលអាហារូបករណ៍ទៅសិក្សានៅ HARWORD។

. កាលនៅក្មេងចេះតែខំរៀនទៅ លោកគ្រូចៅអធិការប្រាប់ថា និមន្តរៀនទៅពីព្រោះចំណេះវិជ្ជានេះ ជាអ្វីគ្រប់យ៉ាងទាំងអស់ល្អ ជាគ្រាប់ពេជ្រ ជាមរតកអ្វីដែលមនុស្សលោកអាចទទួលយកបាន ។ ចឹងក៏ស្រឡាញ់ ចាប់ផ្តើមស្រឡាញ់សិក្សា ហើយក៏ចេះតែរៀនមករហូតទល់ពេលនេះ។

**សំណួរ** តើមូលហេតុអ្វី បានជាព្រះតេជគុណខិតខំបន្តការសិក្សា មិនត្រឹមតែក្នុងវិស័យព្រះពុទ្ធសាសនាទេតែថែមទាំងផ្នែកបច្ចេកទេសផងដែរ រហូតដល់បន្តការសិក្សានៅក្រៅប្រទេសទៀត?

**សង្ឃដីការព្រះអង្គ**

យល់ថា ចំណេះដឹងជាទ្រព្យដ៏ល្អ ទ្រព្យមានតម្លៃ ហើយរៀនទៅក៏បានឃើញផលដែលទទួលបានតាមរយៈចំណេះដឹង និងការស្វែងយល់អំពីជីវិតខ្លួនឯង បានគួរសមច្រើនជាងមុនព្រមទាំងតម្រូវការនិងសង្គមដែលទាមទារឱ្យមានចំណេះដឹងថែមទៀត។

**សំណួរ** តើកត្តាអ្វីខ្លះ ដែលជម្រុញឱ្យព្រះតេជគុណបន្តការអានរហូតមក ?

**សង្ឃដីការព្រះអង្គ**

ឆន្ទៈ និងការពេញចិត្តនៃការចង់អាន ចង់ចេះ ចង់ដឹង យើងត្រូវព្យាយាមចិញ្ចឹមឆន្ទៈប្រៀបបានដូចជាការអប់រំចិត្តរាល់ថ្ងៃដើម្បីឱ្យមានចិត្តហ្នឹងស្ងប់។ ដូច្នេះ បើចង់ឱ្យមានឆន្ទៈការសិក្សានេះឱ្យនៅថេរក្នុងដួងព្រលឹងរបស់យើង គឺត្រូវចិញ្ចឹមវា និងទី២តម្រូវការក្នុងវិស័យការងារដែលមិនអាចខ្វះបានធ្វើឱ្យព្រះអង្គ បានខិតខំសិក្សាស្រាវជ្រាវបន្ថែម។

**សំណួរ** តើកត្តាអ្វីខ្លះ ដែលធ្វើឱ្យលោកសាស្ត្រាចារ្យបណ្ឌិត មានជោគជ័យក្នុងការសិក្សាកន្លងមករហូតអាចទទួលបានអាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេសតាំងពីឆ្នាំទសវត្សឆ្នាំ១៩៧០ ហើយមានកត្តាអ្វីខ្លះទៀតដែលនាំឱ្យលោកសាស្ត្រាចារ្យបណ្ឌិតនៅបន្តសរសេរ និពន្ធ រហូតមកដល់សព្វថ្ងៃនេះ ?

**លោកសាស្ត្រាចារ្យ**

តាមបទពិសោធន៍របស់លោកសាស្ត្រាចារ្យបណ្ឌិត លោកបានបង្ហាញថា ដោយសារមានបរិយាកាសគ្រួសារបានបង្កើតឱ្យលោកមានចំណង់ចំណូលចិត្ត ស្រឡាញ់សៀវភៅ ចង់តាមដាន ចង់អាន ដែលជាមូលដ្ឋានបណ្តុះការស្រឡាញ់ការអាន រួមទាំងការឱ្យតម្លៃលើការអាននេះផងដែរពីកត្តាសង្គម ។

**សំណួរ** តើកត្តាអ្វីខ្លះដែលជម្រុញឱ្យលោកសាស្ត្រាចារ្យរៀបចំជាវេបសាយក៏ដូចជាឯកសារRenaissance នេះឡើង និង នៅក្នុងការរៀបចំជួបការលំបាកឬយ៉ាងណាដែរ ?

**លោកសាស្ត្រាចារ្យ**

. ការរៀបចំមុនដំបូងនោះ ជាទស្សនាវដ្តីមួយមានកម្រិត Academic ឈ្មោះ "ឧទ័យ" ដែលកំពុងមានជីវិតដល់សព្វថ្ងៃនេះ។បន្ទាប់ពីបានបោះពុម្ពផ្សាយមកឃើញថាអត់បានជ្រួតជ្រាបដល់ស្រទាប់ខាងក្រោម។ពេលហ្នឹងគិតថាធ្វើយ៉ាងណាឱ្យគេចាប់បានទាំងក្មេង ទាំងចាស់ អ្នកមានវិជ្ជាល្មមៗ អាចចាប់ផ្តើមអានបាន ជួនជាពេលនោះ អ៊ិនធ័រណែតនៅស្រុកខ្មែរ បានចាប់ប្រើប្រាស់គួសមដែរទើបបង្កើតខ្មែរ Renaissance ហ្នឹងមកដើម្បីសរសេរអត្ថបទជាភាសាជាតិឱ្យខ្លីៗ។

**សំណួរ** តើព្រះអង្គយល់ឃើញថាយ៉ាងណាដែរ អំណាននេះអាចផ្លាស់ប្តូរទៅជាប្រព័ន្ធឌីជីថលជារូបភាពជាវីដេអូវិញ តើវាខុសគ្នា ឬ ព្រះអង្គយល់ថាវានឹងគាំទ្រគ្នាយ៉ាងណាដែរ ?

**សង្ឃដីការព្រះអង្គ**

. ព្រះតេជគុណគិតថា នេះមិនមែនមកពីនិស្ស័យរបស់កូនចៅយើងខ្ជិលអានទេ អាចមកពីរបត់ថ្មីមួយនៅក្នុងសម័យបច្ចុប្បន្ន ព្រោះគេប្រើដូចយើងដែរគេនៅតែអាន មេចក៏យើងមិនអាន ពិសេសរបត់ជីវិតថ្មីនេះ គឺធ្វើឱ្យយើងទទួលយកនូវស្នាតហ្វូនដែលជាប្រព័ន្ធបច្ចេកវិទ្យាថ្មី។

. បើយើងមើលវីដេអូវាលឿន តែបើអានវាយឺត ចំពោះពិសោធន៍របស់ព្រះអង្គ បើអានសំណេរ និងមើលវីដេអូគឺការអានវាជិតជាមហើយហាក់ដូចជា បានឆ្លងពីពិភពមួយចូលទៅកាន់ពិភពមួយទៀតតាមរយៈសំណេរនេះហើយមានបង្ហាញទាំងជាតិនិយម វប្បធម៌ អក្សរសាស្ត្រ សីលធម៌ គុណធម៌ទាំងអស់បានហូរជ្រាបទៅគ្រប់តួរអក្សរខ្មែរ។

**សំណួរ** តើយើងអាចមានវិធីយ៉ាងណា ដើម្បីធ្វើឱ្យការទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធអាចជ្រាបបានដល់សាធារណៈជនបានប្រសើរជាងមុន ?

**សង្ឃដីការព្រះអង្គ**

. ព្រះត្រៃបិតកបានបកប្រែតាំងពីឆ្នាំ២០ជាងមកម៉្លេះ។ ដូច្នេះ ភាសាបាលីដែលប្រើរាល់ថ្ងៃនេះ ជាភាសាបែបបុរាណច្រើន និងរហូតមកដល់ពេលនេះ មិនទាន់មានអ្នកប្រាជ្ញណាមួយទាន់សម្រួលភាសាហ្នឹងឱ្យមកងាយអានទេ ប្រហែលជាត្រូវប្រើប្រាស់ពេលវេលាយូរទៀត។

. ទាក់ទងនឹងការបង្រៀនព្រះពុទ្ធសាសនាក្នុងសម័យបច្ចុប្បន្ន ដោយសារតែគម្ពីរធំៗរបស់ព្រះពុទ្ធសាសនាសរសេរជាភាសាបុរាណច្រើនបានធ្វើឱ្យព្រះសង្ឃចាប់ផ្តើមសរសេរ តែការសរសេរនោះមិនសូវសរសេរបានច្រើនទេ បានត្រឹមតែសមល្មម យកភាសាក្នុងបាលីហ្នឹង មកបកប្រែជាភាសាបាលី សម្រាប់ប្រើបច្ចុប្បន្ន។

**សំណួរ** តើអត្ថបទដែលសរសេរជាភាសាអង់គ្លេស នៅក្នុងបណ្ណាល័យដែលព្រះតេជគុណបានឃើញនៅទីនោះមានលក្ខណៈខុសគ្នាពីសៀវភៅ ពីព្រះពុទ្ធសាសនានៅស្រុកខ្មែរយើងយ៉ាងម៉េចខ្លះដែរ?

**សង្ឃដីការព្រះអង្គ**

ព្រះពុទ្ធសាសនាមិនខុសគ្នាទេគឺគេកាន់សាសនាបែបថេរវាទដូចគ្នាដែរ ប៉ុន្តែអ្វីដែលអាចខុសគ្នាបន្តិចបន្តួចត្រង់ការបដិបត្តិសាសនាតាមប្រទេសនីមួយៗ ហើយក៏ជះឥទ្ធិពលទៅលើស្រុកនោះ រួមទាំងវប្បធម៌ផងដែរ។

**សំណួរ** អ្វីដែលព្រះតេជគុណបានទៅរៀនពីបច្ចឹមប្រទេសតើបានយកមកបន្សុីគ្នាបែបណាជាមួយនឹងទំនៀមទំលាប់ប្រពៃណីរបស់ព្រះពុទ្ធសាសនាកម្ពុជាយ៉ាងដូចម្តេចដែរ?

**សង្ឃដីការព្រះអង្គ**

. ចំណេះវិជ្ជាទាំងនោះវាមិនមានខុសគ្នាពីស្រុកយើងទេ គឺយើងទទួលបានទាំងអស់

. ភារៈជាអ្នកបួស មិនអាចផ្លាស់ប្តូរអីឱ្យលើសពីហ្នឹង គឺមិនមានទេព្រោះទំនៀមនេះគេរក្សាមក ២៥៦៦ ឆ្នាំមកហើយ អត់អាចមកដូរត្រឹមឆ្នាំ ២០២៣បានទេ ហើយប៉ុណ្ណឹងក៏សមល្មមនិងស្រួលផងដែរ។

. ព្រះតេជគុណគិតថាដើម្បីយល់ ស្រឡាញ់ អំពីអត្តសញ្ញាណទាំងអស់នេះ ទាមទារឱ្យអ្នកបួសត្រូវតែវិលត្រឡប់ទៅសិក្សាគម្ពីរដីការក្បួនច្បាប់របស់ខ្លួនឡើងវិញ ដែលនេះគឺទាមទារឆ្លងកាត់តាមការអាន។

. បុគ្គលណាដែលអានច្រើន បុគ្គលណាមួយដែលស្តាប់ច្រើន ព្រះពុទ្ធជាម្ចាស់ហៅថាជាអ្នកប្រាជ្ញ ជាអ្នកចេះដឹង លោកហៅថា ពហុសូត្រ។ សូត្រប្រែថា ស្តាប់, ពហុប្រែថាច្រើន ដូចនេះពហុសូត្រ ប្រែថា ស្តាប់ច្រើន មានន័យថាអ្នកចេះដឹង។

**សំណួរ** តើអ្វីជាការជម្រុញឱ្យព្រះអង្គ អានហើយអានទៀត អត់ឈប់អត់ឈរ?

**សង្ឃដីការព្រះអង្គ**

យើងអាន យើងចេះ អត់មានអ្នកដែលអានច្រើនណា ក្លាយជាមនុស្សដែលអវិជ្ជាទេ នេះជាចំណុចដែលពេញចិត្តការអាន។ យើងអាន យើងមើលឃើញ យើងទទួលរស់ជាតិ និងទទួលអត្ថប្រយោជន៍ពីការអាន។ ម្យ៉ាងទៀត យើងចេះតែអានយូរៗទៅ យើងនឹងទទួលស្គាល់ថា ការអាននេះ ពិតជាមានតម្លៃ។

**សំណួរ** តើលោកសាស្ត្រាចារ្យបណ្ឌិត មានវិធីសាស្ត្របែបណាខ្លះក្នុងការនិពន្ធ ឬសរសេរឯកសារដែលបោះពុម្ពកន្លងមកជាភាសាបរទេសមកបោះពុម្ពចេញជាភាសាខ្មែរវិញ?

**លោកសាស្ត្រាចារ្យ**

ខ្មែរRenaissance នេះ មិនមែនលោកបណ្ឌិតជាអ្នកនិពន្ធ សរសេរជាភាសាខ្មែរ ម្នាក់ឯងទេ គឺមានអ្នក និពន្ធច្រើនផ្សេងៗ ដោយលោកគ្រាន់តែជាអ្នកជំរុញឃោសនាឱ្យសរសេរ ឱ្យរកអត្ថបទខ្លីៗកុំឱ្យវែង

ខ្លាំងពេកមិនដល់កម្រិតសៀវភៅទេ គឺយកមកពិនិត្យមើល ស្រាវជ្រាវ ក្នុងគោលបំណង ដើម្បីឱ្យអ្នកដែលមិនដឹង មិនទាន់យល់ពីរឿងនោះ បានដឹងនិងយល់ពីបញ្ហាផ្សេងៗដែលកើតមាន។

**សំណួរ** តើមានកត្តាគន្លឹះអ្វីខ្លះក្នុងការតែងនិពន្ធ ដើម្បីឱ្យមានការកោតសរសើរ និងជក់ចិត្តស្នាដៃនិពន្ធពីអ្នកអាន?

**លោកសាស្ត្រាចារ្យ**

ការសរសេរផ្សារភ្ជាប់នឹងឈ្មោះពិត កាលបរិច្ឆេទពិត។ ប្រសិនបើ មានភាពមិនច្បាស់លាស់ មិនពិត យើងត្រូវបញ្ជាក់ថា រឿងហ្នឹងថាជារឿងប្រឌិត។ លោកបានលើកឧទាហរណ៍ថា លោកបានសរសេររឿងសត្វលោក ការដាក់ពាក្យសត្វលោកនេះព្រោះក្នុងរឿងហ្នឹងជាអមនុស្សដូចជា អ្វីជាម្រេញគង្វាល អ្វីជាម្តាយដើមជាដើម ព្រមទាំងបញ្ជាក់ថា នេះជារឿងប្រឌិត ។

**សំណួរ** តើមានគន្លឹះ និងវិធីសាស្ត្រអ្វីខ្លះ សម្រាប់រក្សាឱ្យបានលក្ខណៈប្រវត្តិសាស្ត្រក្នុងការសរសេរតែងនិពន្ធ?

**លោកសាស្ត្រាចារ្យ**

មុននឹងសរសេររឿងប្រលោមលោកបែបប្រវត្តិសាស្ត្រ យើងត្រូវស្គាល់ច្បាស់ពីទីកន្លែងនោះ ហើយក៏មិនហ៊ាននិយាយអ្វីដែលខុសពីការពិតដែរ។ តែចំណុចខ្លះ ទីកន្លងមានពិត តែបើមិនចាំពីពេលវេលា ដូចនេះ លោកសរសេរបញ្ជាក់ថា នេះជារឿងប្រឌិតទេ។

**សំណួរ** តើគួរតែនិពន្ធ និងសរសេរបែបណា ឬមានផែនការយ៉ាងណាដែរ ដើម្បីយកធម៌វិន័យឱវាទរបស់ព្រះពុទ្ធ មកប្រើក្នុងជីវភាពប្រចាំការរស់នៅរបស់ប្រជាជន?

**សង្ឃដីការព្រះអង្គ**

មានផែនការរួចមកហើយ តែដោយកិច្ចការនេះមានទំហំធំ ខ្វះធនធានអ្នកចេះបកប្រែពីភាសាបាលីមកជាសំរាយចបាស់លាស់ ទើបយើងមិនទាន់ហ៊ានធ្វើ ព្រោះយើងមិនចង់ឱ្យបាត់បង់ភាពដើម និងរក្សាភាពដើម ប៉ុន្តែនេះ ជាកិច្ចការសំខាន់ដែលយើងនឹងត្រូវធ្វើនៅពេលមុខ។

**សំណួរ** តើអាចមានការនិពន្ធយកធម៌វិន័យរបស់ព្រះពុទ្ធសាសនាមកសរសេរជាសាច់រឿងសម្រាប់អប់រំដោយមានលក្ខណៈងាយយល់ សម្រាប់ប្រជាជនពិសេសក្មេងៗជំនាន់ក្រោយបែបណាដែរ ឬ ទេ?

**សង្ឃដីការព្រះអង្គ**

ព្រះអង្គធ្លាប់សរសេររឿងខ្លីមួយ " **រឿងព្រះពុទ្ធនៅក្នុងវិហារ** " ដើម្បីអប់រំដល់ពុទ្ធបរិស័ទក៏ដូចជាព្រះសង្ឃ ឱ្យចេះថែរក្សាទ្រព្យសម្បត្តិ សម្ភាតវត្ត ថែរក្សាសមិទ្ធិផលវត្ត ដូចជាព្រះវិហារ ព្រះពុទ្ធបដិមាករ និងបណ្តុះស្មារតីឱ្យចេះទទួលខុសត្រូវនូវអ្វីដែលខ្លួនបាននិយាយ និងបានធ្វើ ដើម្បីបោះពុម្ពផ្សព្វផ្សាយ ។

**កម្មវិធីសំណួរពីមហាជន**

១. លោក **អ៊ឹង សុកក្តិវិនិច្ឆ័យ** ជានិស្សិតអក្សរសាស្ត្រខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានសំណួរ ៖

១. តើមនុស្សខ្មែរពីបុរមបុរាណមក គាត់ចូលចិត្តអាន ដែរឬទេ?

២. តើការបញ្ជ្រាបផ្នត់គំនិតបែបណា ដើម្បីឱ្យខ្មែរមានការចូលចិត្តអាន?



២. លោកគ្រូបង្រៀនភាសាថៃ និងភាសាអង់គ្លេស មានសំណូមពរនិងសំណួរ៖

សំណូមពរ ៖ ស្នើសុំតម្លៃសៀវភៅ មានតម្លៃថោក ងាយទិញ ងាយយកទៅអាន និងប្រើប្រាស់

សំណួរ ៖ តើអានធ្វើមេចឱ្យអានឆាប់ចាំ?

៣. លោកស្រី **គីម ស** ជាអ្នកសារព័ត៌មាន មកពីសារព័ត៌មាន AMS មានសំណួរ ៖



១. តើលោកសាស្ត្រាចារ្យបណ្ឌិត មានជំនឿជាក់ថា អំណាន ពិតជាមាគ៌ាឆ្ពោះទៅរកបរិវត្តកម្មវិស័យអប់រំដែរ ឬទេ?
